៣-លោកជំទាវ **ស៊ីវណ្ណា បុទុម** រដ្ឋលេខាធិការក្រសួងកិច្ចការនារី អនុប្រធាន

៤-ឯកឧត្តម **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

៥-ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៦-ឯកឧត្តម **អេង ហួត** រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

៧-ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន

៨-លោកជំទាវ **ប្រាក់ ចន្ថា** រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៩- ឯកឧត្តម **ខឹម ទិសិដ្ឋ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១០-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃុន ខុច** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១១-ឯកឧត្តម **ខឹង ប៊ុនថេង** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ សមាជិក

១២-ឯកឧត្តម **ទូច ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៣-លោកជំទាវ **តឹករ៉េត គំរេង** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១៤-ឯកឧត្តម **រិន វីរៈ** អនុរដ្ឋលេខាធិការក្រសួងផែនការ សមាជិក

១៥- ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១៦- លោកជំទាវ **ម៉ាត់ ម៉ារ៉ា** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៧-លោកជំទាវ **ធឹង ស៊ីមន** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

១៨-លោកជំទាវ **មីន មាណាវី** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១៩-លោកជំទាវ **ម៉ី ប៊ុតវិឌ្ឍា** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

២០-ឯកឧត្តម **សៅ ខិន** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

២១-ឯកឧត្តម **គឹម ទូច** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែនិងថាមពល សមាជិក

២២-ឯកឧត្តម **ហោ សារុន** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

២៣-លោកជំទាវ **ច័ន្ទ ធី** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

២៤-ឯកឧត្តម **ខិញ ហាឡហួន** អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា សមាជិក

២៥-ឯកឧត្តម **ហាង ឡារ៉ាម៉ានី** តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក

២៦-លោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការសមាគមជាតិកាកបាទក្រហមកម្ពុជា សមាជិក

២៧-លោកស្រី **ដួង វឌ្ឍនី** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី សមាជិក

២៨-ឯកឧត្តមឧត្តមសេនីយ៍ឯក **លី គឹមឡុង** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

២៩-លោកស្រី **ខៀវ បូរី** អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិកអចិន្ត្រៃយ៍

**មាត្រា ២.-**

សមាជិក សមាជិកា នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានភារកិច្ចអនុវត្តតួនាទី និងភារកិច្ច ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខនស/រកត/១២០៩/១២០១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១៩៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ ប្រគេន ព្រះតេជគុណ ឆាន ផន ព្រះចៅអធិការវត្តព្រៃតុម្ព ដែលបានបរិច្ចាគបច្ច័យ ចំនួន ៥២.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា និងអប់រំ នៅវត្តព្រៃតុម្ព ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៩៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តព្រៃតុម្ព ឃុំព្រៃតុម្ព ស្រុកទឹកឈូ ខេត្តកំពត ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| ១- | លោក | ទ្រឹន ឡាំ | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកា ១០.០០០ ដុល្លារ |
| ២- | លោក | ហេង យ៉ុង | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១០.០០០ ដុល្លារ |
| ៣- | លោក | ហង្ស ប៊ុនឡេង | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១០.០០០ ដុល្លារ |
| ៤- | អ្នកស្រី | អ៊ាប គីនី | សប្បុរសជននៅខេត្តកំពត | ថវិកា ១០.០០០ ដុល្លារ |
| ៥- | លោក | ជា ប៊ុនហេង | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកា ១០.០០០ ដុល្លារ |
| ៦- | អ្នកស្រី | លី ជេគដួង | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកា ១០.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| - | ឧបាសក | ជា មិត្ត | សប្បុរសជននៅខេត្តកំពត | ថវិកា ៥.០០០ ដុល្លារ |

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង ស្រះទឹក ខឿនដើមពោធិ ចាក់សាបសាលាធម្មសភា ចាក់ដីក្នុងទីធ្លាវត្ត បង្គន់អនាម័យ ស្ថិតនៅវត្តដងទង់ ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| ១- | ព្រះគ្រូ | **នេព ចាន់** | ព្រះចៅអធិការវត្តដងទង់ | បច្ច័យ ១០.០០០ ដុល្លារ |
| ២- | អ្នកស្រី | **សូដាន់ យឹមសែ** | សប្បុរសជនរស់នៅសហរដ្ឋអាមេរិក | ថវិកា ១២.០០០ ដុល្លារ |

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| ១- | ព្រះតេជគុណ | **ទូត ម៉េងឈុន** | គង់នៅរាជធានីភ្នំពេញ | បច្ច័យ ១.២៥០ ដុល្លារ |
| ២- | ព្រះតេជគុណ | **ឃុល គីមហៃ** | គង់នៅរាជធានីភ្នំពេញ | បច្ច័យ ១.១៧៥ ដុល្លារ |
| ៣- | ឧបាសិកា | **កៅ សាម៉ន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.៥២០ ដុល្លារ |
| ៤- | អ្នកស្រី | **កៅ គីន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.៣៧២ ដុល្លារ |
| ៥- | អ្នកស្រី | **ស៊ូ គីន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.៣៥០ ដុល្លារ |

៦- អ្នកស្រី **មាស សារិន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា ១.១៣០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតាំងស៊ប់លោកស្រី **សៅ តេជារ័ត្ន** ទៅក្នុងឋានន្តរស័ក្តិ**មន្ត្រីបច្ចេកទេសមធ្យម** ថ្នាក់លេខ ១៥ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ តទៅ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច* /
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកំណត់សមាសភាពគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២១១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីបង្កើតគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់សមាសភាពគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ដែលមានរាយនាមដូចខាងក្រោម:

១. ឯកឧត្តម នាយឧត្តមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន

២. ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣. ឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី និងជាអនុប្រធាននៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម អនុប្រធាន

៤. ឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន អនុប្រធាន

៥. ឯកឧត្តម នាយឧត្តមសេនីយ៍ **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន

៦. ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន

៧. ឯកឧត្តម **ខាន់ សារឿន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៨. ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ អនុប្រធាន

៩. ឯកឧត្តម ឧត្តមនាវីឯក **ទៀ វិញ** មេបញ្ជាការកងទ័ពជើងទឹក អនុប្រធានប្រចាំការ

១០. ឯកឧត្តម **ចក់ ឡេង** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១១. ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១២. ឯកឧត្តម **សំ សារិត** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក

១៣. ឯកឧត្តម **ប៉ៅ ទ្រី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៤. ឯកឧត្តម **សួន រចនា** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១៥. លោកជំទាវ **ចាន់ សុទ្ធាវី** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១៦. ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

១៧. ឯកឧត្តម **ខុង សំនួន** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

១៨. ឯកឧត្តម **គាន់ គឹមរិន់** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១៩. ឯកឧត្តម **គីម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

២០. ឯកឧត្តម **គោស៊ុំ សារឿត** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

២១. លោកជំទាវ **អ៊ុក ម៉ាលី** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា សមាជិក

២២. ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស សុភា** អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក សមាជិក

២៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក **សៅ សុខា** អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

២៤. ឧត្តមសេនីយ៍ឯក **ស៊ឹង សំណាង** មេបញ្ជាការកងទ័ពជើងអាកាស សមាជិក

២៥. ឯកឧត្តម ឧត្តមសេនីយ៍ឯក **យូ ស៊ុនឡុង** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

២៦. ឯកឧត្តម **ញៀម សុខារ័ត្ន** អនុប្រធានប្រចាំការរបស់លេខាធិការដ្ឋានគណៈកម្មាធិការ ជាតិប្រឆាំងភេរវកម្ម សមាជិក

២៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ណឹម សុវត្ថិ** អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និង កិច្ចការបរទេស នៃក្រសួងការពារជាតិ សមាជិក

២៨. ឯកឧត្តម **ប៉ែន ស៊ីម៉ន** អគ្គនាយកគយ និងរដ្ឋាករកម្ពុជា សមាជិក

២៩. ឯកឧត្តម **ម៉ក់ ពេជ្ជរិទ្ធ** អគ្គនាយកកាំកុងត្រូល សមាជិក

៣០. ឯកឧត្តម **រស់ វណ្ណា** អគ្គនាយកកាំសាប សមាជិក

៣១. ឯកឧត្តម **លូ គឹមឈន់** អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សមាជិក

៣២. ឯកឧត្តម **ហ៊ី បាវី** អគ្គនាយកកំពង់ផែស្វយ័តក្រុងភ្នំពេញ សមាជិក

៣៣. ឯកឧត្តម **ណៅ ធួក** អគ្គនាយករដ្ឋបាលជលផល សមាជិក

៣៤. ឯកឧត្តម **ហួ វិចិត្រ** អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា សមាជិក

៣៥. ឯកឧត្តម **ស្បោង សារ៉ាត់** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ សមាជិក

៣៦. ឯកឧត្តម **ខូយ ឃុនហួរ** អភិបាលនៃគណៈអភិបាលខេត្តកំពត សមាជិក

៣៧. ឯកឧត្តម **ហាស់ សារ៉េត** អភិបាលនៃគណៈអភិបាលខេត្តកែប សមាជិក

៣៨. ឯកឧត្តម **ប៊ុន លើត** អភិបាលនៃគណៈអភិបាលខេត្តកោះកុង សមាជិក

៣៩. ឧត្តមសេនីយ៍ឯក **សួន សំណាង** អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការ បរទេស និងជានាយក នាយកដ្ឋាននយោបាយផែនការ នៃក្រសួងការពារជាតិ សមាជិកប្រចាំការ

៤០. ឧត្តមសេនីយ៍ទោ **ម៉ម សំ** នាយកខុទ្ទកាល័យ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិកប្រចាំការ

៤១. ឧត្តមសេនីយ៍ទោ **ហ៊ូ សាគុណ** ប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក នៃអគ្គស្នងការ ដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ សមាជិក

៤២. ឧត្តមសេនីយ៍ត្រី **ហ៊ុន ម៉ាណែត** មេបញ្ជាការនៃបញ្ជាការដ្ឋានកម្លាំងពិសេសប្រឆាំង ភេរវកម្ម នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម សមាជិក

៤៣. លោក **សូ ណាសុត** នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក

៤៤. លោក **ប៊ុន រដ្ឋា** នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាប សមាជិក

៤៥. លោក **ទិត្យ វន្ធា** នាយកអាកាសយានដ្ឋានខេត្តព្រះសីហនុ សមាជិក

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៩៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ២៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ព្រះវិហារ ឧបដ្ឋានសាលា កុដិ ឯងទង់ របង ខ្លោងទ្វារ ចេតិយ៍ បង្គន់អនាម័យ សំណាក់អាស្រម និងអណ្តូងទឹក នៅវត្តញរ ស្ថិតក្នុងឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដូចមានរាយព្រះនាម និងនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ:**

| | | | | |
|---|---|---|---|---|
| ១- | ព្រះតេជគុណ | សោម ឈ្នៅ | ព្រះចៅអធិការវត្តញរ | បច្ច័យ ១០.១២៧ ដុល្លារ |
| ២- | លោក | ស៊ិន ឃិន | អគ្គនាយករងអមទីស្តីការគណៈរដ្ឋមន្ត្រី | ថវិកា ១៣.៣៨៥ ដុល្លារ |
| ៣- | អ្នកស្រី | កើត ថាន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១២.០៥០ ដុល្លារ |
| ៤- | លោក | សួស ភន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកា ១១.០០០ ដុល្លារ |
| ៥- | ឧបាសិកា | ព្រាប យ៉ាន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកា ១០.៥០០ ដុល្លារ |
| ៦- | លោក | ទៀម ធិត្យ | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១០.១៤៥ ដុល្លារ |
| ៧- | ឯកឧត្តម | ជ័យ សុន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១០.១៣៥ ដុល្លារ |
| ៨- | អ្នកស្រី | ព្រាប សាម៉ុត | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១០.១១៧ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ៩- | លោក | អៀម ឧត្តម | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១០.១១២ ដុល្លារ |
| ១០- | លោក | ព្រាប សារុន | សប្បុរសជននៅខេត្តសៀមរាប | ថវិកា ១០.១០០ ដុល្លារ |

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

| | | | | |
|---|---|---|---|---|
| - | ឯកឧត្តម | ជា ម៉ន | មេបញ្ជាការភូមិភាគទី៤ | ថវិកា ៥.៦៧៥ ដុល្លារ |

គ-មេដាយសំរឹទ្ធស្ថាបនាជាតិ:

| | | | | |
|---|---|---|---|---|
| ១- | លោក | ចាញ់ សុខ | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ៣.៧០០ ដុល្លារ |
| ២- | ឧបាសិកា | សោម ចេន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ២.៤៧០ ដុល្លារ |
| ៣- | ឧបាសិកា | គង់ សាខន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ២.៤០០ ដុល្លារ |
| ៤- | លោក | នុត អោក | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ២.២២៨ ដុល្លារ |
| ៥- | ឧបាសក | នង ផាត់ | អាចារ្យវត្តញរ | ថវិកា ១.៥៣៥ ដុល្លារ |
| ៦- | អ្នកស្រី | ឡុង សាទិន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.៤៦៨ ដុល្លារ |
| ៧- | ឧបាសិកា | មោង យឹម | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.១៣០ ដុល្លារ |
| ៨- | លោក | កើត ផូ | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.១០៥ ដុល្លារ |
| ៩- | ឧបាសិកា | នង ម៉ុច | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកា ១.០៦៥ ដុល្លារ |
| ១០- | លោក | សឿ សំអាន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកា ១.០៦៥ ដុល្លារ |
| ១១- | ឧបាសិកា | ពិន ខ្សែ | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកា ១.០៥០ ដុល្លារ |
| ១២- | លោក | គីម ញឹម | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.០៥០ ដុល្លារ |
| ១៣- | លោក | ចាន់ ថន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ១.០២៥ ដុល្លារ |

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៩៩ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាភិបាល
## នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូស្វ័យគ្រាសាស្ត្រ និងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ៤៤ អនក្រ. បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលខ្លឹមសារមាត្រា ៥ ជំពូកទី ២ ផ្នែកទី១ នៃអនុក្រឹត្យលេខ ១១៥ អនក្រ. បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្មជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម អាណត្តិទី ៣ ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- លោក | **ម៉ែន** | **ស៊ីផាន់** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- លោក | **ឡុង** | **សុខា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- លោក | **រស់** | **បរម** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- លោក | **វ័ត្ត** | **សុខា** | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៥- លោក | **ភុជ** | **សុខាន** | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៦- លោក | **ថេង** | **ច័ន្ទសង្វារ** | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧- សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | | | | សមាជិកស្វ័យប្រវត្តិ |
| ៨- លោកស្រី | **ចាន់** | **ផលលឿន** | តំណាងក្រុមប្រឹក្សាស្រាវជ្រាវកសិកម្ម | សមាជិក |
| ៩- លោកស្រី | **សុខ** | **សុន្ទាទី** | តំណាងសភាពាណិជ្ជកម្ម | សមាជិក |
| ១០- លោក | **សរ** | **សុវណ្ណា** | តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១- លោក | **ឈុំ** | **ភិតភលន់** | តំណាងបុគ្គលិកសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិកស្វ័យប្រវត្តិ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រធានសភាពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..២០០..អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅក្នុងឋានន្តរស័ក្តិក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការ គិតចាប់ពីថ្ងៃទី **០៦** ខែ **សីហា** ឆ្នាំ **២០០៩** ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | **គីម សំភារៈ** | ប | មន្ត្រីក្រមការ | ថ្នាក់លេខ **១១** |
| ២ | **សុខ ម៉ុនធីរៈ** | ប | មន្ត្រីក្រមការ | ថ្នាក់លេខ **១១** |

**មាត្រា ២ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| **តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៩ តទៅ** | | | | |
| ១ | **យី ឡុងឌី** | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |
| ២ | **សៅ ដារ៉ា** | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |
| ៣ | **ឈាន សុខរ៉ុន** | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |
| ៤ | **ពេជ្រ ខន** | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩ តទៅ | | | | |
| ៥ | **ឡាន ម៉ុនណា** | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |

| | | | | |
|---|---|---|---|---|
| **តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ តទៅ** | | | | |
| ៦ | សេស តាតា | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៧ | ធិត សុវណ្ណឌី | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| **តាំងស៊ប់គិតចាប់ពីថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៩ តទៅ** | | | | |
| ៨ | ធា វី | ប | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៩ | សន សុគន្ធា | ស | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |

**មាត្រា ៣ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅក្នុងក្របខ័ណ្ឌ គ្រូបង្រៀនកម្រិតមូលដ្ឋាន គិតចាប់ពីថ្ងៃទី ០១ ខែ **មេសា** ឆ្នាំ **២០០៩** ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១ | គូ លន់ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២ | អោក ឡៃស៊ី | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣ | ជា ម៉ុនថន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤ | ញៀត ហេម | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥ | គួយ សុខឡាយ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៦ | ឃី ច័ន្ទរា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៧ | កែវ ថាច | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៨ | ស៊ាង ធារី | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៩ | ហ៊ុន គីមហ៊ន់ | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១០ | នុំ សុគន្ធា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១១ | ញ៉ៅ សុផារណារ៉ាត់ | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១២ | សេង សុធា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៣ | សេង ស៊ីថា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៤ | ម៉យ វិសាល | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៥ | ម៉ៅ កែវចាន់ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៦ | ឡេង ភូឡា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៧ | ស្រី ស៊ីវឌ្ឍនា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ១៨ | ជឹម សត្យា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |

| | | | | |
|---|---|---|---|---|
| ១៩ | សាន់ សេ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២០ | នៅ សារឿន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២១ | ជុំ ថេត | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២២ | សាំង រ៉ូហ៊ឿត | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២៣ | សយ ដាលីន | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២៤ | អ៊ែល ទិចិត្រា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២៥ | នាង ធូរិន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២៦ | ជួន កុម្ភះ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២៧ | ឈី សៀវពេញ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២៨ | សុខ សុទ្ធី | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ២៩ | ខួន ទីន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣០ | នាយ ពិសិដ្ឋ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣១ | ប៉ែន សុខន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣២ | រុល អាត | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣៣ | នាង សោរិន្ធី | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣៤ | អឿន នួច | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣៥ | ស្រេង ស៊ីទី | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣៦ | ហេង្ស សំបុក | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣៧ | យៀង ហាក់ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣៨ | អាន សុវណ្ណា | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៣៩ | តាន់ សុខគី | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤០ | ស ចិន្តា | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤១ | ពយន ឈុនលាង | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤២ | លី វណ្ណា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤៣ | គង់ សំណាង | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤៤ | ប៉ែន ខេមរិន្ទ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤៥ | អ៊ុន សុខនី | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |

| | | | | |
|---|---|---|---|---|
| ៤៦ | អ៊ំ សំអន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤៧ | ជា ចាន់ណា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤៨ | ម៉ា សូរិយា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៤៩ | យឹម បូរីយុទ្ធ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥០ | ទឹម សាឡុត | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥១ | ខៀវ ខេមរិន្ទ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥២ | អ៊ុំ វាសនា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥៣ | សូ ចុត្រា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥៤ | ឆៀប សារ៉ាត | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥៥ | វ៉ាន់ សុធារ៉ា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥៦ | ប៉ុច ចន្ថា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥៧ | លឹម សុខហ៊ត់ | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥៨ | សំ សាវ៉ាត | ស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៥៩ | ម៉ុច សុចិត្រា | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៦០ | ម៉ុ គីន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៦១ | សៅ សុធានី | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |
| ៦២ | ហម សៀងហឿន | ប | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ថ្នាក់លេខ ១៤ |

**មាត្រា ៤ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួងសុខាភិបាល ទៅក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលមធ្យម នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ដូចមានរាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| **តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៨** | | | | |
| ១ | ឆ៉ាត់ ម៉ុន្និកា | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ២ | យ៉ាង វិចិត្រ | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ៣ | សុភ្រ ខ្មែរសាខ | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ៤ | គង់ ចន្ថា | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| **តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩** | | | | |
| ៥ | ព ពយ | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១១ |

| | | | | |
|---|---|---|---|---|
| ៦ | ស៊ូ គឹមឆា | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១១ |
| ៧ | ស៊ឹម វណ្ណៈ | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ៨ | សៀន ភារម្យ | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ៩ | សៅ វណ្ណដេត | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១០ | សំ សុគន្ធផល្លា | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១១ | ឡាញ ស៊ីដន | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១២ | អ៊ឹម សុខលី | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១៣ | ហួត សុធន់ | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១៤ | ទម៉ែ រតនា | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១៥ | សុន សាទីរ៍ | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១៦ | អ៊ុយ ឫទ្ធី | ប | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| ១៧ | អ៊ុក សុធាវី | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |
| **តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៨** | | | | |
| ១៨ | នួន វិច្ឆិកា | ស | មន្ត្រីសុខាភិបាលមធ្យម | ថ្នាក់លេខ ១៤ |

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ មាត្រា ២ មាត្រា ៣ និងមាត្រា ៤ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧០.១..អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ត្រូវបានដាក់លោក **ឡេវ នី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** មុខតំណែងសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ឱ្យចូលនិវត្តន៍ តាមមុខតំណែងក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ចាប់ពីថ្ងៃទី **៣១** ខែ **ធ្នូ** ឆ្នាំ **២០០៩** តទៅ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្ត អនុក្រឹត្យ នេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា "២"
- រាជកិច្ច ✓
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន **Mr. WANIBE SHINJI** ដែលបានផ្តល់ថវិកាសរុបចំនួន ៤៧.០០០ ដុល្លារអាមេរិក តាមរយៈអង្គការ **School Aid Japan** ក្នុងការជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន០៤បន្ទប់ ជូនដល់អនុវិទ្យាល័យទឹកហូត ស្ថិតនៅក្នុងឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ហ MR

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ២ ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦១ . សសរ

# សេចក្តីសំរេច

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖
១-វរសេនីយ៍ទោ **ហ៊ឹម ដារ៉ា** អត្តលេខ ០២៥៩៩១ ជា នាយការិយាល័យអនុព័ន្ធយោធា អមស្ថានបេសកកម្ម អចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក
២-វរសេនីយ៍ត្រី **ណុប ម៉ិនថន** អត្តលេខ ០២១៨៥៩ ជាជំនួយការរដ្ឋបាលនិងបច្ចេកទេស អនុព័ន្ធយោធា អមស្ថានបេសកកម្ម អចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១៧..សសរ.

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលប្រការ១ និងប្រការ៥ នៃសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញសេចក្តីសម្រេចលេខ៥៣ សសរ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា

## សម្រេច

**ប្រការ១មួយៈ** ប្រការ១ និងប្រការ៥ នៃសេចក្តីសម្រេចលេខ៥៣ សសរ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា ត្រូវបានកែសម្រួល ដូចខាងក្រោម

**ប្រការ១ថ្មីៈ** សមាសភាពគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា មានដូចខាងក្រោម

១- ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធាន

២- ឯកឧត្តម បណ្ឌិតវេជ្ជ **គិច សំណាង** អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា អនុប្រធានអចិន្ត្រៃយ៍

៣- ឯកឧត្តម **សុខ តាង** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៤- ឯកឧត្តម **ហ៊ាន សាហ៊ីប** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម **អ៊ឹម បុណ្ណា** ប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃរាជបណ្ឌិតសភាកម្ពុជា សមាជិក

៦- ឯកឧត្តម **ប៉ក់ ថាវិន** អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៧- ឯកឧត្តម **អើ ណៃលាង** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៨- ឯកឧត្តម **ឡៅ ហ៊ីម** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៩- លោក ឧត្តមសេនីយ៍ត្រី **ណុប ធី** ប្រធានមន្ទីរចាត់ការនៃបណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ សមាជិក

១០- លោក ឧត្តមសេនីយ៍ទោ **នាង អេង** អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា និងជានាយកនាយកដ្ឋានអប់រំ នៃក្រសួងការពារជាតិ សមាជិក

១១- លោក **ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ** អគ្គនាយករង អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១២-លោក **យក់ សុធាន់ណា** សាកលវិទ្យាធិការរង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នៃក្រសួងសុខាភិបាល សមាជិក

១៣-ព្រះមហា **ផាន់ ធឿន** មន្ត្រីសង្ឃនៃពុទ្ធិកសាកលវិទ្យាល័យព្រះស៊ីហនុរាជនៃក្រសួងធម្មការ និងកិច្ចការសាសនា សមាជិក

១៤-លោក **ប៉ែន ស៊ីថុល** ប្រធាននាយកដ្ឋានស្តង់ដារ និងការទទួលស្គាល់គុណភាពអប់រំនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សមាជិក

១៥-លោក **ស សាម៉ុឌី** ប្រធាននាយកដ្ឋាននីតិកម្ម និងវិវាទមុខងារសាធារណៈនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

១៦-លោក **លាង សេងហាក់** ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងក្រឹតការ នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៧-លោកស្រី **ម៉ក់ ណារាង** អនុប្រធាននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៨-លោក **ម៉ិត សុម៉េត** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សមាជិក

១៩-លោក **ថៃ ឧុទ្ធី** អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

**ប្រការ៥ថ្មី:** - គណៈកម្មាធិការត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយមានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីសំរួលការងារ។ សមាសភាព និងតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋាន អចិន្ត្រៃយ៍ ត្រូវកំណត់ដោយគណៈកម្មាធិការ។

- ថវិកាសម្រាប់ជានាដំណើរការការងាររបស់គណៈកម្មាធិការ និងលេខាធិការដ្ឋាន អចិន្ត្រៃយ៍ ត្រូវស្នើឡើងដោយគណៈកម្មាធិការ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការពីរ:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខៈ...០០១............គ ម ក

លិខិតចូល
ថ្ងៃទី០៧...ខែមីនា...ឆ្នាំ២០១០

## ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ÷

១-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ ÷

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ប្រាក់បង់លើស (Premium) សំដៅដល់ទឹកប្រាក់ដែលបានទទួលពីការលក់មូលបត្រកម្មសិទ្ធិលើសពីតម្លៃចារឹក។

៥-ភាគហ៊ុនបុរិមា (Preference Share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៦-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៧-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

៨-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

៩-ភ្នាក់ងារទូទាត់ជំនួស (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១០-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១១-មូលធនភាគហ៊ុនិក (Shareholders' Equity) សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

១២-របាយការណ៍ហិរញ្ញវត្ថុ សំដៅដល់របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលក្នុងនោះរួមមាន របាយការណ៍របស់អភិបាល របាយការណ៍របស់សវនករឯករាជ្យ និងរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មរួច។

១៣-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

ប្រការ ៣.-

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូលបត្រកម្មសិទ្ធិជាឯកជន ៖

១-សំណើលក់មូលបត្រដែលធ្វើឡើង ចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់ អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក គ.ម.ក. ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវរាយការណ៍ពីលទ្ធផលឱ្យបានឆាប់ជូន គ.ម.ក.។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន គ.ម.ក.។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ ក្នុងអនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖

១-ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៥.០០០.០០០.០០០ (ប្រាំពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

២-ត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធិយ៉ាងតិច ២០ (ម្ភៃ) ភាគរយនៃមូលធនភាគហ៊ុនិកសរុប សម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកសរុបតិចជាង ២០.០០០.០០០.០០០

(ម្ភៃពាន់លាន) រៀល និងត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធិយ៉ាងតិច ១៥ (ដប់ប្រាំ) ភាគរយនៃមូលធនភាគហ៊ុនិកសរុប សម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកសរុបចាប់ពី ២០.០០០.០០០.០០០ (ម្ភៃពាន់លាន) រៀល ឡើងទៅ។

៣-ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ៥០០.០០០.០០០ (ប្រាំរយលាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងមានផលចំណេញសរុបសម្រាប់រយៈពេល ០៣ (បី) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយចំនួន ១.០០០.០០០.០០០ (មួយពាន់លាន) រៀល។

៤-ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥-ត្រូវទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុតលើការដាក់តម្លៃមូលបត្រដែលធ្វើសំណើលក់។

**ប្រការ ៥.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ ៖

១-ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២-ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣-ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា ១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៧ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាលនាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានមាតិកាដូចខាងក្រោម ៖

១-ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

២-ព័ត៌មានស្តីពីកត្តាហានិភ័យ

៣-ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤-ផែនការវិនិយោគ

៥-ការពិពណ៌នាអំពីធុរកិច្ច

៦-ការពិពណ៌នាអំពីអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ

៧-ផែនការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ

៨-ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩-ព័ត៌មានពាក់ព័ន្ធនឹងអភិបាល និងបុគ្គលិកជាន់ខ្ពស់

១០-ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១-ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២-ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣-សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤-ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥-ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦-កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧-ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨-ការពិពណ៌នាពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩-ព័ត៌មានហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ

២០-ព័ត៌មានហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុរួម។

**ប្រការ ៨.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានការពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ០១ (មួយ) ផែនការនីមួយៗ ត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវមានព័ត៌មានទូទៅដូចខាងក្រោម ៖

១-ឈ្មោះក្រុមហ៊ុនដាក់ពាក្យស្នើសុំ

២-ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣-តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤-ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៥-ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៦-កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧-សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ ក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម ÷

១-ហានិភ័យអត្រាការប្រាក់

២-ហានិភ័យអត្រាប្តូរប្រាក់

៣-ហានិភ័យក្នុងវិស័យធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ

៤-ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៥-ហានិភ័យពាក់ព័ន្ធនឹងសកម្មភាពមិនមែនប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុន

៦-ហានិភ័យពាក់ព័ន្ធនឹងទីផ្សារ និងបច្ចេកវិទ្យា

៧-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តនៃបទប្បញ្ញត្តិ

៨-ហានិភ័យពាក់ព័ន្ធនឹងការវិវត្តនៃបរិការណ៍ជាតិ និងអន្តរជាតិ។

**ប្រការ ១១.-**

ឯកសារផ្តល់ព័ត៌មាន ត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យ បានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មាន ត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវប្រើប្រាស់ សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុន

បោះផ្សាយ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ និងត្រូវភ្ជាប់កិច្ចសន្យានោះជាឧបសម្ព័ន្ធរបស់ឯកសារផ្តល់ព័ត៌មានដែលស្នើសុំចុះបញ្ជីនេះ។

**ប្រការ ១២.-**

ឯកសារផ្តល់ពត៌មានត្រូវបញ្ជាក់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ របស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា ៖

១-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

២-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៣-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៤-វិធីសាស្ត្រចែកចាយផលិតផល។

៥-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៦-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលជាធាតុដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៧-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៨-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

៩-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬផ្តល់សេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុបរបស់អ្នកផ្គត់ផ្គង់នោះ ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១១-ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១២-សន្ទានុភាពនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៣-ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ពត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើ ក្នុងរយៈពេល ០៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

## ប្រការ ១៣.-

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្ម្សបីរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម ÷

១-ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្ម្សបីរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្ម្សបីទាំងនោះ។

២-សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្ម្សបីរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្ម្សបីទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្ម្សបី។

៣-ការវាយតម្លៃលើអចលកម្ម្សបីរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលបានចុះបញ្ជីនៅ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

៤-ប្រសិនបើអចលកម្ម្សបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

## ប្រការ ១៤.-

នៅក្នុងឯកសារផ្តល់ព័ត៌មាន បុគ្គលដាក់ពាក្យស្នើសុំត្រូវបង្ហាញផែនការប្រតិបត្តិការសង្ខេបសម្រាប់រយៈពេល ០៣ (បី) ឆ្នាំ ដូចខាងក្រោម ÷

១-ការប៉ាន់ស្មានចំណេញភាព និងចលនាសាច់ប្រាក់រយៈពេល ១២ (ដប់ពីរ) ខែ ដែលត្រូវបានពិនិត្យឡើងវិញ និងរាយការណ៍ដោយសវនករឯករាជ្យ។

២-ការរំពឹងទុកអំពីការផ្លាស់ប្តូរបុគ្គលិកចំនួនច្រើន។

៣-ប្រភពសាច់ប្រាក់ខាងក្នុង និងខាងក្រៅ។

៤-ការចំណាយមូលធនសំខាន់ៗ និងប្រភពមូលនិធិសម្រាប់ការចំណាយនោះ។

៥-បុព្វហេតុដែលបណ្តាលឱ្យមានការប្រែប្រួលពីពេលមួយទៅពេលមួយនៃប្រាក់ចំណូល ថ្លៃដើមទំនិញដែលបានលក់ ចំណាយប្រតិបត្តិការផ្សេងៗ និងចំណេញសុទ្ធ។

៦-ទិដ្ឋភាពតាមរដូវកាលនៃធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ។

៧-និន្នាការ ព្រឹត្តិការណ៍ ឬភាពមិនប្រក្រតីណាមួយ ដែលមានផលប៉ះពាល់ខ្លាំងលើធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយក្នុងពេលអនាគត។

៨-រាល់ការផ្លាស់ប្តូរចំពោះទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ដែលត្រូវប្រើប្រាស់សម្រាប់ទូទាត់បំណុល។

៩-សេចក្តីបញ្ជាក់ពីកម្ចីសំខាន់ៗ រវាងក្រុមហ៊ុនហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធនៅពេលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

១០-រាល់កិច្ចសន្យាពាក់ព័ន្ធនឹងបំណុលនាពេលអនាគតដែលអាចកើតមាន និងផលប៉ះពាល់នៃបំណុលនោះលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។

១១-ចំណាយមូលធនប៉ាន់ស្មាន។

១២-រាល់អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ ពន្ធគយ ឬបំណុលពន្ធផ្សេងៗ ដែលមិនទាន់បានទូទាត់ រួមទាំងបំណុលជាយថាហេតុ ដោយបញ្ជាក់ពីមូលហេតុនៃការមិនទាន់បានទូទាត់មុនពេលចេញផ្សាយឯកសារផ្តល់ពត៌មាន។

១៣-សេចក្តីលម្អិតអំពីភតិសន្យាប្រតិបត្តិការសំខាន់ ដែលក្រុមហ៊ុនបោះផ្សាយបានចុះកិច្ចសន្យា ដោយបញ្ជាក់ឱ្យបានច្បាស់នូវលក្ខខណ្ឌនៃភតិសន្យា។

១៤-សេចក្តីលម្អិតអំពីបញ្ញត្តិនានាពាក់ព័ន្ធនឹងបុគ្គលិកក្រុមហ៊ុនបោះផ្សាយ។

១៥-សេចក្តីលម្អិតអំពីចំណាយទាំងអស់ ដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបង្ហាញជាពិសេសនូវកម្រៃសម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ។

១៦-របាយការណ៍របស់សវនករពាក់ព័ន្ធនឹងគោលនយោបាយលើកទឹកចិត្តរបស់ក្រុមហ៊ុនបោះផ្សាយតាមរយៈការបែងចែងជាមូលបត្រកម្មសិទ្ធិ តម្លៃតបស្នង ឬជាសាច់ប្រាក់ដូចមានកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

**ប្រការ ១៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្តីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។ ក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញឈ្មោះ គុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ និងហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃឡើងវិញ ដោយបង្ហាញពីតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម ៖

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអាណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-សេចក្តីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ប្រសិនបើមាន។

៦-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ០៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

ឯកសារដូចខាងក្រោម ត្រូវភ្ជាប់នៅក្នុងឯកសារផ្តល់ព័ត៌មាន ៖

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញនូវព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងរយៈពេល ១០ (ដប់) ឆ្នាំចុងក្រោយ ដូចខាងក្រោម ÷

១-បណ្តឹងពាក់ព័ន្ធនឹងក្ស័យធន ធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬ អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ច ចំពោះ អភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយល្បួរ ឬ ដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬ សកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយល្បួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្ម ភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗ ក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើត ចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់ព័ន្ធដូចខាងក្រោម ÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ។

២-បុគ្គលដែលមានភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិ កំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣-សមាជិកគ្រួសារផ្ទាល់ (រួមមាន ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬ បងប្អូនស្រី) របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤-បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រ សម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះ កើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះ ផ្សាយ។

៥-បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៦-អភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីក្រុមហ៊ុនបោះផ្សាយ។

៧-អភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

## ប្រការ ១៩.-

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម ÷

១-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ០៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣-ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤-ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥-ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

## ប្រការ ២០.-

ព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល ឬបុគ្គលិក ត្រូវមាននៅក្នុងឯកសារផ្តល់ព័ត៌មាន ដោយត្រូវបញ្ជាក់នូវ ÷

១-កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២-ថ្លៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣-ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤-ថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

## ប្រការ ២១.-

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាន នូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទនិងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោល ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

## ប្រការ ២២.-

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

## ប្រការ ២៣.-

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ០៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ។ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ០៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់ពួក

គេម្នាក់ៗ ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ជាសាធារណៈ។

ប្រសិនបើថ្លៃលក់មូលបត្រកម្មសិទ្ធិខ្ពស់ជាងតម្លៃចារឹក ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញនូវអំណះអំណាងអំពីប្រាក់បង់លើស ដោយផ្អែកលើ ៖

១-តម្លៃទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ដោយឈរលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ (Historical Cost) ឬថ្លៃដើមបច្ចុប្បន្ន (Current Cost)។

២-តម្លៃចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ដែលគណនាដោយឈរលើមូលដ្ឋាននៃមធ្យមទម្ងន់នៃប្រាក់ចំណេញសុទ្ធក្រោយការបង់ពន្ធរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយបន្តបន្ទាប់គ្នា ឬរយៈពេលខ្លីជាងនេះ ដោយគិតពីពេលចាប់ផ្តើមធ្វើប្រតិបត្តិការពាណិជ្ជកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៣-តម្លៃចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលប៉ាន់ស្មាន សម្រាប់រយៈពេល ០៣ (បី) ឆ្នាំនៃឆ្នាំសារពើពន្ធខាងមុខ ដោយឈរលើមូលដ្ឋានចំណេញប៉ាន់ស្មាន។ ការព្យាករណ៍ត្រូវតែធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ ហើយត្រូវពិនិត្យឡើងវិញ និងរាយការណ៍ ដោយសវនករឯករាជ្យ។

៤-តម្លៃក្នុងមួយឯកតាគិតជាមធ្យមក្នុងទីផ្សារនៃមូលបត្រកម្មសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែមុនការធ្វើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬតម្លៃក្នុងមួយឯកតាគិតជាមធ្យមក្នុងទីផ្សារនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែដូចគ្នា ក្នុងករណីការបោះផ្សាយនោះជាសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈឡើងវិញ។

៥-កត្តាផ្សេងទៀតដោយបញ្ជាក់អំណះអំណាងថាក្រុមហ៊ុនបោះផ្សាយធ្លាប់បានយកមកប្រើសម្រាប់កំណត់ប្រាក់បង់លើស។

៦-គំរូផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.** ក្នុងការគណនាតម្លៃក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធទៅនឹងសិទ្ធិផ្សេងៗភ្ជាប់ជាមួយមូលបត្រកម្មសិទ្ធិដែលជាកម្មវត្ថុនៃសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដូចខាងក្រោម ៖

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជំរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និងព័ត៌មានហិរញ្ញវត្ថុព្យាករណ៍ ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្ម ស្របទៅតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

**ប្រការ ២៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម និងព័ត៌មានហិរញ្ញវត្ថុព្យាករណ៍រួម ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់មករបាយការណ៍ហិរញ្ញវត្ថុរួមដែលរៀបចំ និងធ្វើសវនកម្ម ស្របតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

**ប្រការ ២៨.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ម្ចាស់

យោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែងរបាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

**ប្រការ ២៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ៣០.-**

បុគ្គលដាក់ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម ៖

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៣-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤-លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬនាយកប្រតិបត្តិ ក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយ ដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥-កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជស្តីពីការបើកគណនីដាច់ដោយឡែក សម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៧-កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

៨-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

៩-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១០-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១១-លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់ជំនួស។

១២-កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនបើមាន។

១៣-លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬលិខិតបញ្ជាក់ពីសវនករនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន។

១៤-របាយការណ៍អនុសាសន៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៥-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យករជំនាញដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៦-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍ លើការចុះបញ្ជីឯកសារផ្តល់ព័ត៌មានក្នុងរយៈពេល ០២ (ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំ ផ្តល់ព័ត៌មានបន្ថែម ឬព័ត៌មានជំនួស ឬសេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីបុគ្គលដាក់ពាក្យស្នើសុំមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣៣.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់បុគ្គលដាក់ពាក្យស្នើសុំដោយផ្អែកលើមូលហេតុដូចខាងក្រោម ៖

១-បុគ្គលដាក់ពាក្យសុំមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែក នូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ៖

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាត ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ ៖

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

ឌ-ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៤.-**

បុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី ៖

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើ ពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.**។

**ប្រការ ៣៥.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីអំពីការធ្វើបរិវិសកម្មនោះភ្ជាប់មក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលមានអាជ្ញាប័ណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សា

ទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែក នៅធនាគារពាណិជ្ជដូច មានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវ តែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្ម នីមួយៗ ត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មបានបំពេញត្រឹមត្រូវ តាម ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញ ដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញ បានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៩ និងប្រការ ៤០ នៃប្រកាសនេះ។

**ប្រការ ៣៦.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិន អស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើ បរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់នោះ និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុន បោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្ម មូលបត្រកម្មសិទ្ធិដែលនៅសល់ មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៧.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម ÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់ អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិ ខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើ បោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៨.-**

ក្រុមហ៊ុនមូលបត្រ ត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្ងៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ភ្នាក់ងារបញ្ជិកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិ ឬវិញ្ញាបនបត្រមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្មក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៩.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើ ចំពោះសំណើលក់ជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម ៖

១-លេខសេរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះ ត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤១.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន អាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ ឬនៅពេលក្រុមហ៊ុនបោះផ្សាយមិនអាចបញ្ចប់ការចែកចាយមូលបត្រកម្មសិទ្ធិអស់ តាមពេលកំណត់ដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.គ.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែកដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមូលបត្រកម្មសិទ្ធិ ឬវិញ្ញាបនបត្រមូលបត្រកម្មសិទ្ធិត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម ដូចមានកំណត់ក្នុងប្រការ ៣៩ នៃប្រកាសនេះដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៤.-**

ក្រុមហ៊ុនបោះផ្សាយ ត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.គ.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៥.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.គ.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

ក្រុមហ៊ុនបោះផ្សាយត្រូវតែរៀបចំឯកសារផ្តល់ព័ត៌មាន ដើម្បីត្រៀមទុកផ្តល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការយល់ព្រមពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៦.-**

រយៈពេលយ៉ាងតិច ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការ តាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយ ដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម ៖

១-ឈ្មោះ និងប្រទេស ឬស្ថាប័នផ្សេងៗទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២-ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣-ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤-កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការយល់ព្រមជាគោលការណ៍ពី **គ.ម.ក.** រួចហើយ។

៦-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧-កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ នឹងចាប់ផ្តើម។

៨-សេចក្តីថ្លែងដែលបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ត្រូវពិចារណា ដោយផ្អែកទៅលើឯកសារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមលើនេះ ក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិក ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិកឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## តម្លៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៧.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សានិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៤៨.-**

បុគ្គលដាក់ពាក្យស្នើសុំធ្វើការពិនិត្យ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម ត្រូវបង់សោហ៊ុយ សម្រាប់ការពិនិត្យ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ករណីសំណើបោះផ្សាយ-លក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៤៩.-**

បុគ្គលដាក់ពាក្យស្នើសុំដែលមានបំណងឱ្យ **គ.ម.ក.** ធ្វើការពិនិត្យឡើងវិញចំពោះសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលអស់សុពលភាព ត្រូវបង់សោហ៊ុយពិនិត្យឡើងវិញ នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ។

២-ជាសាច់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម។

**ប្រការ ៥០.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយដូចមានចែងក្នុងប្រការ ៤៧ ប្រការ ៤៨ និងប្រការ ៤៩ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៥១.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម ÷

១-ការស្នើឱ្យដាក់អនុស្សារណៈ។

២-ការព្រមាន ឬការដាស់តឿន។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥-ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥២.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ៥៣.-**

គ.ម.ក. អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្ត តាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៥៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៥.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១០

**គាត ឈន់**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
 នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-គណៈកម្មការមូលបត្រកម្ពុជា
 "ដើម្បីជូនជ្រាប"
-ដូចប្រការ ៥៥
 "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ ០០៧ គ ម ក

លិខិតចូល

ថ្ងៃទី០៣ ខែ០៣ ឆ្នាំ២០១០

# ប្រកាស

## ស្ដីពី

## អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ/បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវធានាឱ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អ តាមរយៈការបង្កើតយន្តការដើម្បីការពារសិទ្ធិរបស់ភាគហ៊ុនិក ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន ការកំណត់សិទ្ធិអំណាចនិងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ការបង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ ស្របតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ៤.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ៖

១-ក្រុមប្រឹក្សាភិបាល សំដៅដល់បុគ្គលមួយក្រុមដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគហ៊ុនិកតាមរយៈមហាសន្និបាតភាគហ៊ុនិក ហើយមានសិទ្ធិអំណាចអនុវត្តភារកិច្ចដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន។

២-គណៈកម្មាធិការសវនកម្ម សំដៅដល់គណៈកម្មាធិការមួយនៃក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ រាល់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការត្រួតពិនិត្យខាងក្នុង និងខាងក្រៅ ព្រមទាំងសវនកម្ម។

៣-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការវិភាគ វាយតម្លៃ តាមដាន និងរាយការណ៍អំពីហានិភ័យរបស់ក្រុមហ៊ុន ព្រមទាំងគ្រប់គ្រងហានិភ័យទាំងនោះ។

៤-គណៈកម្មាធិការតែងតាំង សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការពិនិត្យឡើងវិញ និងវាយតម្លៃ អំពីគុណវឌ្ឍិបុគ្គលទាំងឡាយដែលជាបេក្ខភាពសម្រាប់ការតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលទទួលបានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

៥-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៦-បុគ្គលិកជាន់ខ្ពស់ សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានរហូតដល់អគ្គនាយក រួមទាំងលេខាធិការក្រុមហ៊ុន និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៧-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច សំដៅដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចំនួនតិចជាង ០៥ (ប្រាំ) ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន។

៨-សមាជិកគ្រួសារផ្ទាល់ សំដៅដល់ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស បងប្អូនស្រី។

៩-សវនករឯករាជ្យ សំដៅដល់សវនកររបស់ក្រុមហ៊ុនគណនេយ្យជំនាញដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ហើយដែលទទួលស្គាល់ដោយ គ.ម.ក.។

១០-សែល្ហ៍ដៀលីង (Self-Dealing) សំដៅដល់ទង្វើរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស អ្នកផ្តល់ប្រឹក្សាច្បាប់ បុគ្គលិករបស់ក្រុមហ៊ុន ឬក៏បុគ្គលពាក់ពន្ធ័នឹងកិច្ចសន្យាដែលទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួន នៅក្នុងប្រតិបត្តិការណាមួយ។

១១-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

១២-អភិបាលឯករាជ្យ សំដៅដល់សមាជិកឯករាជ្យដែលមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រង ផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅដែលមិនសមស្រប។

១៣-អភិបាលប្រតិបត្តិ សំដៅដល់អភិបាលដែលមានមុខតំណែងជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

១៤-អភិបាលមិនប្រតិបត្តិ សំដៅដល់អភិបាលដែលមិនមែនជាអភិបាលប្រតិបត្តិ។

## ជំពូកទី ២
## ភាគហ៊ុនិក

### ប្រការ ៥.-

សិទ្ធិជាមូលដ្ឋានរបស់ភាគហ៊ុនិក ដែលបានកំណត់ដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមិនត្រូវបានដកហូតឬរឹតត្បិតដោយការចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុនឡើយ។ ភាគហ៊ុនិកត្រូវទទួលបាននូវការគោរព និងការពារសិទ្ធិទាំងនេះ ពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុន។

ភាគហ៊ុនិកមានសិទ្ធិទទួលបានការចុះបញ្ជីជាកម្មសិទ្ធិករលើបណ្ណភាគហ៊ុនប្រកបដោយសុវត្ថិភាព សិទ្ធិក្នុងការផ្ទេរ ឬកាត់កងបណ្ណភាគហ៊ុន សិទ្ធិទទួលបាននូវព័ត៌មានពីក្រុមហ៊ុន សិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក និងអនុវត្តសិទ្ធិបោះឆ្នោត ដូចជា សិទ្ធិបោះឆ្នោតជ្រើសតាំង ដកចេញ ឬជំនួសនូវសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់។

**ប្រការ ៦.-**

ការជ្រើសរើសអភិបាលត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន។ ភាគហ៊ុនិកមានសិទ្ធិធ្វើការបោះឆ្នោតជ្រើសតាំង ដកចេញ ឬជំនួស នូវអភិបាល ព្រមទាំងការបោះឆ្នោតអនុម័តនូវកិច្ចការផ្សេងៗរបស់ក្រុមហ៊ុន តាមរយៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកក្នុងរូបភាពដោយផ្ទាល់ តាមរយៈអាណត្តិគាហកៈ។

**ប្រការ ៧.-**

ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ភាគហ៊ុនិកម្នាក់ៗអាចពិនិត្យបញ្ជីឈ្មោះរបស់ភាគហ៊ុនិកទាំងឡាយបាន នៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងដែលរក្សាទុកបញ្ជីមូលបត្រនោះ នៅក្នុងម៉ោងធ្វើការ ឬនៅពេលប្រជុំមហាសន្និបាតភាគហ៊ុនិកដែលបញ្ជីឈ្មោះត្រូវបានរៀបចំ។

ក្រុមហ៊ុនគួរតែមានគេហទំព័រមួយដែលអាចឱ្យភាគហ៊ុនិក និងសាធារណជនអាចទទួលបានព័ត៌មាន។ ភាគហ៊ុនិកអាចទទួលបាននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច លទ្ធផលប្រតិបត្តិការ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ព្រមទាំងព័ត៌មានរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ តាមរយៈគេហទំព័ររបស់ក្រុមហ៊ុន និងព័ត៌មានផ្សេងទៀតអំពីក្រុមហ៊ុន។ ប្រសិនបើក្រុមហ៊ុនមិនមានគេហទំព័រទេ ភាគហ៊ុនិកអាចធ្វើសំណើសុំថតចម្លងឯកសារដូចរៀបរាប់ខាងលើ ដោយតម្រូវឱ្យបង់ថ្លៃសមរម្យសម្រាប់ការបោះពុម្ព និងការចែកចាយឯកសារទាំងនោះ។ ភាគហ៊ុនិកមានសិទ្ធិទទួលបានទាន់ពេល អំពីព័ត៌មានដែលបានរៀបរាប់ខាងលើ។

**ប្រការ ៨.-**

ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ភាគហ៊ុនិកដែលប្រមូលផ្តុំសម្លេងបានចាប់ពី ៥១ (ហាសិបមួយ) ភាគរយឡើងទៅ មានសិទ្ធិស្នើឱ្យអភិបាលរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ និងស្នើឡើងនូវកម្មវត្ថុដើម្បីដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំដែលកម្មវត្ថុទាំងនោះមាន ដូចជា ការកែតម្រូវលក្ខន្តិកៈក្រុមហ៊ុន បញ្ហាអភិបាលកិច្ចរបស់ក្រុមហ៊ុន ការប្រែប្រួលមូលធន ព្រមទាំងកម្មវត្ថុផ្សេងទៀតដែលអនុញ្ញាតដោយលក្ខន្តិកៈក្រុមហ៊ុន។

អភិបាលមានសិទ្ធិកោះប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ និងវិសាមញ្ញ។

**ប្រការ ៩. -**

ក្រុមប្រឹក្សាភិបាលត្រូវតែការពារផលប្រយោជន៍របស់ភាគហ៊ុនិកទាំងអស់ និងត្រូវការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច រួមមាន ÷

-សិទ្ធិស្វែងរកព័ត៌មាន

-សិទ្ធិក្នុងការបញ្ចេញយោបល់

-សិទ្ធិស្នើកែតម្រូវ។

ក្រុមប្រឹក្សាភិបាលត្រូវធានាធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងអន្តរកម្មរវាងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច បុគ្គលិកជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវស្នើសុំការអនុម័តពីភាគហ៊ុនិក លើការកែតម្រូវនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន អំពីប្រព័ន្ធបោះឆ្នោតត្រួតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។ ករណីទទួលបានការអនុម័ត ប្រព័ន្ធបោះឆ្នោតត្រួតនេះត្រូវបានអនុវត្តនៅរាល់កិច្ចប្រជុំ។

**ប្រការ ១០. -**

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនដែលមានថ្នាក់ដូចគ្នាត្រូវមានសិទ្ធិដូចគ្នា។ នីតិវិធី និងដំណើរការនៃមហាសន្និបាតភាគហ៊ុនិក ត្រូវរៀបចំឡើងក្នុងលក្ខខណ្ឌដែលអនុញ្ញាតឱ្យភាគហ៊ុនិកទទួលបាននូវសិទ្ធិដូចគ្នា។

ភាគហ៊ុនធម្មតាក្នុងមួយភាគហ៊ុន ត្រូវផ្តល់ឱ្យភាគហ៊ុនិកនូវសិទ្ធិបោះឆ្នោតមួយសម្លេង ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ហើយសិទ្ធិបោះឆ្នោតនេះមិនអាចត្រូវបានរឹតត្បិតដោយបុគ្គលណាឡើយ។

ភាគហ៊ុនិកត្រូវតែទទួលបាននូវព័ត៌មានចាំបាច់ និងទាន់ពេល ពីក្រុមហ៊ុនដូចៗគ្នា ដោយគ្មានភាគហ៊ុនិកណាម្នាក់អាចទទួលបានព័ត៌មានដែលមិនទាន់បង្ហាញជាសាធារណៈពីក្រុមហ៊ុននោះទេ។

**ប្រការ ១១. -**

អភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិក មិនត្រូវមានជាប់ពាក់ព័ន្ធ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬសៃហ៊ុយៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនមិនត្រូវធ្វើការជួញដូរមូលបត្ររបស់ក្រុមហ៊ុនក្នុងរយៈពេល ÷

- ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ។

- ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

នៅក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនត្រូវអនុម័ត និងផ្សព្វផ្សាយគោលនយោបាយគ្រប់គ្រងការជួញដូរមូលបត្ររបស់ក្រុមហ៊ុនដែលធ្វើឡើងដោយអភិបាល និងបុគ្គលិក។

**ប្រការ ១២.-**

ភាគហ៊ុនិកត្រូវមានការទទួលខុសត្រូវ ចំពោះការប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួន។ ចំពោះភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ត្រូវតែមានកាតព្វកិច្ចផ្តល់ព័ត៌មានដល់សាធារណជន នៅពេលដែលមានការផ្លាស់ប្តូរចំនួនភាគហ៊ុនដែលខ្លួនកាន់កាប់ ដូចមានចែងក្នុងអនុក្រឹត្យ។

## ជំពូកទី ៣
## ក្រុមប្រឹក្សាភិបាល

**ប្រការ ១៣.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវមានក្រុមប្រឹក្សាភិបាលដែលដឹកនាំ និងត្រួតពិនិត្យក្រុមហ៊ុន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ ក្រុមប្រឹក្សាភិបាលត្រូវតែជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតរបស់ភាគហ៊ុនិក ដែលចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក។

**ប្រការ ១៤.-**

ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកយ៉ាងតិចបំផុតចំនួន ០៥ (ប្រាំ) រូប និងមិនត្រូវលើសពី ១៥ (ដប់ប្រាំ) រូបឡើយ។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវតែមានអភិបាលឯករាជ្យយ៉ាងតិចចំនួន ១/៥ (មួយភាគប្រាំ) នៃចំនួន

អភិបាលសរុប។ ករណីអភិបាលឯករាជ្យជាជនបរទេស អភិបាលនេះត្រូវមានបទពិសោធន៍ការងារនៅកម្ពុជាយ៉ាងហោចណាស់រយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលក្លាយជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុន។

អភិបាលត្រូវមានការទទួលខុសត្រូវច្បាស់លាស់ ក្នុងន័យថា គ្មានបុគ្គលជាអភិបាលណាម្នាក់ ឬបុគ្គលមួយក្រុមតូចណាមួយ អាចគ្របសង្កត់លើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលឡើយ។

**ប្រការ ១៥.-**

ក្រុមប្រឹក្សាភិបាលត្រូវបំពេញតួនាទីរបស់ខ្លួន ប្រកបដោយសុចរិត ជំនាញ និងយកចិត្តទុកដាក់ ដោយអនុវត្តនូវតួនាទីសំខាន់ៗ ដូចខាងក្រោម ៖

១-ត្រូវមានការទទួលខុសត្រូវពេញលេញ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន និងភាគហ៊ុនិក។

២-ត្រូវតែប្រតិបត្តិដោយស្មោះត្រង់ ប្រកបដោយសុឆន្ទៈ និងដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក។

៣-ត្រូវធានាថា ក្រុមហ៊ុនបានធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយភាគហ៊ុនិកនិងភាគីពាក់ព័ន្ធដទៃទៀត។

៤-ធ្វើការកំណត់ តាមដាន និងវាយតម្លៃយុទ្ធសាស្ត្រ គោលនយោបាយ លក្ខណៈវិនិច្ឆ័យ ប្រសិទ្ធភាពគ្រប់គ្រង និងផែនការធុរកិច្ច។

៥-បង្កើត និងតាមដានការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង។

៦-ផ្តល់នូវភាពជាអ្នកដឹកនាំ ដោយដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ព្រមទាំងធានាឱ្យបានថា ធនធានត្រូវបានរៀបចំជាស្រេច ដើម្បីឆ្លើយតបចំពោះគោលដៅដែលបានកំណត់។

៧-អភិបាលមិនត្រូវប្រើអំណាចផ្ទាល់ខ្លួន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល ទៅគាបសង្កត់បុគ្គលិកជាន់ខ្ពស់ នៅក្នុងការអនុវត្តការងាររបស់គេឡើយ។

**ប្រការ ១៦.-**

ក្រុមប្រឹក្សាភិបាលត្រូវរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់យ៉ាងហោចណាស់ ០១ (មួយ) ដងរៀងរាល់ត្រីមាស។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមដោយផ្ទាល់គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ទាំងសាមញ្ញ និងវិសាមញ្ញ។ ករណីក្រុមហ៊ុនមានអភិបាលឯករាជ្យ រាល់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវតែមានវត្តមានរបស់អភិបាលឯករាជ្យយ៉ាងតិច ០១ (មួយ) រូប។

**ប្រការ ១៧. –**

ក្រុមប្រឹក្សាភិបាលត្រូវមានការទទួលខុសត្រូវ ដោយធានាថា កម្រិតនៃប្រាក់បំណាច់ ឬលាភការត្រូវតែសមល្មមដើម្បីទាក់ទាញ និងរក្សាអភិបាលប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់ ដើម្បីភាពជោគជ័យរបស់ក្រុមហ៊ុន។ សមាមាត្រនៃប្រាក់បំណាច់ និងលាភការរបស់អភិបាលប្រតិបត្តិ ត្រូវតែធ្វើយ៉ាងណាឱ្យមានការជាប់ទាក់ទងរវាងរង្វាន់លើកទឹកចិត្តជាមួយនឹងលទ្ធផលរបស់បុគ្គល ក្រុមការងារ និងមាននិរន្តភាពធុរកិច្ចក្រុមហ៊ុនចំពោះភាគហ៊ុនិក។

ក្រុមហ៊ុនត្រូវមានគោលនយោបាយផ្លូវការ និងមានតម្លាភាពស្តីអំពីលាភការ ដោយត្រូវកំណត់កញ្ចប់លាភការ និងប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ឱ្យបានច្បាស់លាស់។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនត្រូវបង្ហាញដោយឡែកអំពីព័ត៌មានស្តីពីប្រាក់បំណាច់ និងលាភការផ្ទាល់ ឬប្រយោលសរុបរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ រួមទាំងអគ្គនាយក។

**ប្រការ ១៨. –**

អភិបាលត្រូវទទួលបានព័ត៌មានពេញលេញ គ្រប់គ្រាន់ និងទាន់ពេល មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តជាគោលការណ៍សម្រាប់ការផ្តល់ព័ត៌មានទាំងនោះជូនក្រុមប្រឹក្សាភិបាល។

បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ជូនក្រុមប្រឹក្សាភិបាលនូវព័ត៌មានពេញលេញ គ្រប់គ្រាន់និងទាន់ពេល។ ករណីចាំបាច់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អ អភិបាលម្នាក់ៗអាចតម្រូវឱ្យបុគ្គលិកជាន់ខ្ពស់ផ្តល់ព័ត៌មានបន្ថែម។

ព័ត៌មានដែលត្រូវផ្តល់ជូនសមាជិកក្រុមប្រឹក្សាភិបាលមានដូចជា សាវតារឿង សេចក្តីពន្យល់លម្អិតពាក់ព័ន្ធនឹងបញ្ហានានា ដែលត្រូវដាក់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ឯកសារផ្តល់ព័ត៌មានថតចម្លង បញ្ជាថវិកាក្រុមហ៊ុន ការព្យាករណ៍ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ។ ពាក់ព័ន្ធនឹងបញ្ជាថវិកា ករណីដែលមានគំលាតណាមួយរវាងគម្រោង និងលទ្ធផលជាក់ស្តែង គឺត្រូវធ្វើការបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់។

**ប្រការ ១៩. –**

អភិបាលត្រូវមានសិទ្ធិដូចខាងក្រោម ÷

១-ទទួលបាននូវរបៀបវារៈ និងព័ត៌មានទាន់ពេល ដើម្បីត្រៀមប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

២-ទទួលបានព័ត៌មានបច្ចុប្បន្នកម្មអំពីក្រុមហ៊ុន។

៣-ជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងសកម្មភាព ឬការសម្រេចចិត្តណាមួយរបស់ក្រុមប្រឹក្សាភិបាល ដោយតម្រូវឱ្យកត់ត្រាឱ្យបានច្បាស់លាស់នូវការបោះឆ្នោតជំទាស់។

៤-ស្នើនូវប្រធានបទពាក់ព័ន្ធណាមួយទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

៥-ជួបជាមួយនឹងបុគ្គលិកជាន់ខ្ពស់ណាម្នាក់តាមការចាំបាច់ ដោយឈរលើភាពសមស្របទៅវិញទៅមក។

៦-ទទួលបានយោបល់លើគ្រប់ភារកិច្ច។

៧-ទទួលបានប្រាក់បំណាច់ ឬលាភការសមរម្យ និងមានតម្លាភាព។

៨-ទទួលបានយោបល់ឯករាជ្យ ប្រសិនបើមានការស្នើសុំ។

**ប្រការ ២០.-**

អភិបាលត្រូវមានមុខងារ និងភារកិច្ច ដូចខាងក្រោម ៖

១-អនុម័តលើគោលនយោបាយ និងនីតិវិធីអនុវត្តសម្រាប់ក្រុមហ៊ុន។

២-ចូលរួមចំណែក និងអនុម័តលើផែនការយុទ្ធសាស្ត្រ។

៣-តាមដាននូវការអនុវត្តគោលនយោបាយ។

៤-ធានាការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។

៥-ទទួលខុសត្រូវចំពោះក្រុមហ៊ុន។

៦-ជ្រើសតាំងនាយកប្រតិបត្តិ។

៧-ធានាសាធនភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន តាមរយៈការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុបានត្រឹមត្រូវ និងការការពារទ្រព្យសកម្មរបស់ភាគហ៊ុនិក។

៨-ផ្តល់នូវភាពជាអ្នកដឹកនាំ ជួយគាំទ្រ និងលើកទឹកចិត្តដល់និយោជិត។

៩-ធានាថា ក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំក្រុមហ៊ុន។

១០-ធានានូវការសម្រេចបានគោលដៅរបស់ក្រុមហ៊ុន។

១១-ផ្តល់នូវទស្សនវិស័យស្តីពីប្រសិទ្ធិភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក។

**ប្រការ ២១.-**

ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវចំពោះភាពជោគជ័យរយៈពេលវែងរបស់ក្រុមហ៊ុន ព្រមទាំងចីរភាពនៃរបៀបប្រកួតប្រជែង ដោយធ្វើយ៉ាងណាឱ្យមានសង្គតិភាពជាមួយនឹងការ

ទទួលខុសត្រូវតាមផ្លូវច្បាប់របស់ខ្លួន ហើយត្រូវធ្វើសកម្មភាពណាដែលបម្រើនូវផលប្រយោជន៍ទាំងស្រុងរបស់ក្រុមហ៊ុន និងភាគហ៊ុនិក។

ក្រុមប្រឹក្សាភិបាលត្រូវធានាថា អភិបាលទទួលការបណ្តុះបណ្តាល ដើម្បីធ្វើបច្ចុប្បន្នកម្មអំពីការវិវត្តនៃអភិបាលកិច្ចសាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលមានផលប៉ះពាល់ដល់ដំណើរការធុរកិច្ចក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលគួរបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំនូវព័ត៌មានស្តីពីការបណ្តុះបណ្តាលអភិបាល។

**ប្រការ ២២.-**

សមាជិកក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចធ្វើការវិនិច្ឆ័យ និងធ្វើសកម្មភាពដោយឯករាជ្យ និងប្រកាន់យកជំហានសមស្របនានា ដើម្បីធានាភាពរឹងមាំនៃការសម្រេចចិត្តរបស់ក្រុម-ប្រឹក្សាភិបាល។ កាតព្វកិច្ចទាំងនោះ រួមមាន ៖

១-ធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនទាំងមូល និងភាគហ៊ុនិក។

២-ប្រើប្រាស់អំណាចឱ្យចំគោលដៅដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនទាំងមូល។

៣-មិនត្រូវផ្ទេរអំណាច លើកលែងតែមានការអនុញ្ញាតត្រឹមត្រូវ និងមានភារកិច្ចដើម្បីអនុវត្ត។

៤-អនុវត្តការងារដោយប្រុងប្រយ័ត្ន ប្រកបដោយភាពជំនាញ និងភាពវាងវៃ។

៥-ដោះស្រាយរាល់ទំនាស់ផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍របស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ។

៦-មិនត្រូវធ្វើប្រតិបត្តិការណាដែលអភិបាលមានផលប្រយោជន៍ លើកលែងតែស្របតាមគោលនយោបាយ និងនីតិវិធីដែលបានអនុម័ត។

៧-មិនត្រូវកេងយកផលប្រយោជន៍ក្នុងមុខតំណែងជាអភិបាល។

៨-មិនត្រូវប្រើប្រាស់ខុសទិសដៅចំពោះព័ត៌មានដែលទទួលបានពីក្រុមហ៊ុន។

៩-មិនត្រូវទទួលយកអំណោយពីតតិយជន ដែលផ្តល់ឱ្យដោយសារតែមុខតំណែងជាអភិបាល។

១០-អនុវត្តតាមលក្ខន្តិកៈក្រុមហ៊ុន និងសេចក្តីសម្រេចផ្សេងៗរបស់ក្រុមហ៊ុន។

១១-ធ្វើសេចក្តីប្រកាសអំពីទំនាស់ផលប្រយោជន៍របស់ខ្លួនដែលកើតមានពាក់ព័ន្ធនឹងក្រុមហ៊ុន។

**ប្រការ ២៣.-**

ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តក្រមសីលធម៌ សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ហើយត្រូវបង្ហាញជាសាធារណៈ។

**ប្រការ ២៤.-**

ក្រុមប្រឹក្សាភិបាលត្រូវតែងតាំងលេខាធិការរបស់ក្រុមហ៊ុន ដើម្បីជាជំនួយការក្នុងការអនុវត្តការងារ។ លេខាធិការរបស់ក្រុមហ៊ុនត្រូវមានលក្ខណសម្បត្តិល្អ មានសញ្ជាតិខ្មែរ ជាបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដោយអនុវត្តការងារល្អ ស្មោះត្រង់ និងមានគោលជំហរនឹងនរ ពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន។

**ប្រការ ២៥.-**

លេខាធិការក្រុមហ៊ុនត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល តាមរយៈប្រធានក្រុមប្រឹក្សា-ភិបាល ហើយត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

១-ត្រូវបង្កើតទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់នានារបស់ក្រុមហ៊ុន។

២-ត្រូវគាំទ្រដល់កិច្ចដំណើរការការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

៣-ត្រូវធ្វើបច្ចុប្បន្នកម្មនូវរាល់ការវិវត្តច្បាប់ និងបទប្បញ្ញត្តិ ដែលអាចមានផលប៉ះពាល់ដល់ក្រុមប្រឹក្សាភិបាល និងប្រតិបត្តិការរបស់ក្រុមហ៊ុន។

៤-ត្រូវធ្វើបច្ចុប្បន្នកម្មអំពីអភិបាលកិច្ចសាជីវកម្ម និងការវិវត្តនៃការទទួលខុសត្រូវសង្គម។

៥-ត្រូវបង្កលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីគាំទ្រដល់ដំណើរការនៃការសម្រេចចិត្ត។

៦-ត្រូវចាត់ចែង រៀបចំ នីតិវិធី និងរក្សាទុក កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុម-ប្រឹក្សាភិបាល និងភាគហ៊ុនិក។

## ជំពូកទី ៤
## ការជ្រើសរើស និងការបញ្ចប់តំណែងសមាជិកក្រុមប្រឹក្សាភិបាល

### ប្រការ ២៦.-

នៅពេលដែលក្រុមហ៊ុនបង្កើតគណៈកម្មាធិការតែងតាំង រាល់ការជ្រើសតាំងបេក្ខភាពអភិបាលត្រូវធ្វើឡើងដោយគណៈកម្មាធិការតែងតាំងដូចមានចែងក្នុងប្រការ ៣៦ នៃប្រកាសនេះ។ ការជ្រើសតាំងត្រូវធ្វើឡើងតាមនីតិវិធីផ្លូវការ និងមានតម្លាភាព ដោយត្រូវធានានូវភាពត្រឹមត្រូវ និងឯករាជ្យ។

គណៈកម្មាធិការតែងតាំងត្រូវតែបញ្ចូលនូវនីតិវិធី ដើម្បីអនុញ្ញាតឱ្យភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចអាចស្នើឡើងនូវបេក្ខភាពអភិបាល។ អភិបាលទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគហ៊ុនិក។

### ប្រការ ២៧.-

គណៈកម្មាធិការតែងតាំងត្រូវពិចារណាលើលក្ខខណ្ឌគុណវុឌ្ឍិរបស់បេក្ខភាពអភិបាលដូចខាងក្រោម ÷

១-នីត្យានុកូលភាព ទេពកោសល្យ សមត្ថភាព និងសុចរិតភាព។

២-មានការប្តេជ្ញាចិត្តខ្ពស់ដើម្បីបម្រើផលប្រយោជន៍របស់ក្រុមហ៊ុននិងភាគហ៊ុនិក។

៣-មានពេលវេលា ថាមពល និងការគាំទ្រដើម្បីបំពេញគ្រប់ភារកិច្ច រួមមានការជួបប្រជុំ និងការចូលរួមសន្និសីទ។

៤-មានលទ្ធភាពធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព។

៥-មានលទ្ធភាពអាចធ្វើការប្រកបដោយប្រសិទ្ធភាពឆ្ពោះទៅរកគោលដៅរួមរបស់ក្រុមហ៊ុន និងភាគហ៊ុនិក ។

៦-យល់អំពីតួនាទីរបស់ខ្លួនជាអភិបាលក្នុងធុរកិច្ច។

៧-មានបទពិសោធន៍យ៉ាងតិច ០៣ (បី) ឆ្នាំ ក្នុងវិស័យពាក់ព័ន្ធជាមួយនឹងមុខតំណែងរបស់ខ្លួន

៨-បង្ហាញអំពីភាពជាអ្នកដឹកនាំ។

៩-មានលទ្ធភាពដើរតួនាទីយ៉ាងសកម្មនៅពេលដែលក្រុមហ៊ុនជួបប្រទះស្ថានភាពវិបត្តិ។

**ប្រការ ២៨.-**

គណៈកម្មាធិការតែងតាំងមិនអាចជ្រើសតាំងបេក្ខភាពអភិបាល នូវបុគ្គលដែលស្ថិតក្នុងស្ថានភាព ដូចខាងក្រោម ÷

១-បុគ្គលនោះធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ។

២-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការមានសមត្ថកិច្ច ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងការបំភាន់ ការកែបន្លំ ការក្លែងបន្លំ ការស្លុកប៉ាន់ ការរំលោភលើសេចក្តីទុកចិត្ត ការញុះញង់ ការសមគំនិត ឬការចូលរួមក្នុងការប្រព្រឹត្តអំពើល្មើសណាមួយ។

៣-បុគ្គលដែលតុលាការបានប្រកាសក្ស័យធនក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ ចុងក្រោយ។

៤-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការបរទេស ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស។

៥-បុគ្គលដែលជាប់ពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ២៩.-**

អភិបាលមិនត្រូវបានបញ្ឈប់ពីតំណែង ឬត្រូវបានបណ្តេញចេញ ដោយគ្មានមូលហេតុត្រឹមត្រូវ និងសមស្របឡើយ និងត្រូវជូនដំណឹងជាមុនទៅអភិបាលនោះដើម្បីជ្រាបជាព័ត៌មាន។

មូលដ្ឋានសម្រាប់ការបញ្ឈប់ ឬការបណ្តេញចេញពីតំណែង រួមមាន ÷

១-ការមិនបង្ហាញព័ត៌មានពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍។

២-ករណីអវត្តមាន ឬមិនបានចូលរួមទាំងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក លើសពី ៥០ (ហាសិប) ភាគរយឡើងទៅ ក្នុង ០១ (មួយ) ឆ្នាំសារពើពន្ធ ទោះបីក្នុងហេតុផលអ្វីក៏ដោយ។

៣-ករណីត្រូវបានព្យួរ បញ្ឈប់ ឬបណ្តេញចេញពីតំណែងជាអភិបាលក្នុងក្រុមហ៊ុនណាមួយ។

៤-អភិបាលឯករាជ្យបានក្លាយជាបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតរបស់ក្រុមហ៊ុន។

៥-អភិបាលឯករាជ្យមានភាគហ៊ុនរបស់ក្រុមហ៊ុនលើសពី ០១ (មួយ)ភាគរយឡើងទៅ។

៦-ត្រូវបានផ្តន្ទាទោសពីបទល្មើសណាមួយ ដូចមានចែងក្នុងប្រការ ២៨។

## ជំពូកទី ៥
## អភិបាលឯករាជ្យ

**ប្រការ ៣០.-**

អភិបាលឯករាជ្យត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយត្រូវបំពេញលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ÷

១-មិនត្រូវបានជួលដោយក្រុមហ៊ុន ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ។

២-មិនមានទំនាក់ទំនងជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់ដ៏សំខាន់របស់ក្រុមហ៊ុន។

៣-មិនមានកិច្ចសន្យាផ្ទាល់ខ្លួនជាមួយក្រុមហ៊ុន ឬជាមួយបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន។

៤-មិនជាប់ទាក់ទងជាមួយអង្គការ ឬសមាគមមិនស្វែងរកប្រាក់ចំណេញណាមួយដែលធ្លាប់ទទួលមូលនិធិពីក្រុមហ៊ុន។

៥-មិនមែនជាសមាជិកក្រុមគ្រួសាររបស់បុគ្គលដែលធ្លាប់ធ្វើជាអភិបាលឱ្យក្រុមហ៊ុន ឬធ្លាប់បានជួលដោយក្រុមហ៊ុន ឱ្យធ្វើជាអគ្គនាយក ឬបុគ្គលិកជាន់ខ្ពស់ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ។

៦-មិនធ្លាប់ធ្វើជាសវនករ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ ឬកំពុងធ្វើជាសវនករឱ្យក្រុមហ៊ុន ។

**ប្រការ ៣១.-**

អភិបាលឯករាជ្យត្រូវមានកាតព្វកិច្ចចូលរួមនៅគ្រប់ការសម្រេចចិត្តសំខាន់ៗរបស់ក្រុមហ៊ុន ព្រមទាំងត្រូវតាមដានត្រួតពិនិត្យ និងគាំទ្រដល់បុគ្គលិកជាន់ខ្ពស់។ ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ថា អភិបាលឯករាជ្យមិនមានទំនាក់ទំនងសំខាន់ជាមួយបុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកដទៃទៀត ដែលអាចនាំឱ្យមានផលប៉ះពាល់ដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យ ដើម្បីបម្រើផលប្រយោជន៍របស់ក្រុមហ៊ុន និងបំពេញនូវតួនាទី ដូចខាងក្រោម ÷

១-ចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយនាំមកនូវការសម្រេចចិត្តឯករាជ្យទៅលើបញ្ហានានា ដូចជា យុទ្ធសាស្ត្រ គោលនយោបាយ ការអនុវត្ត គណនេយ្យភាព ធនធាន ការជ្រើសតាំងបុគ្គលិកជាន់ខ្ពស់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការដឹកនាំ។

២-ត្រូវឈានមុខគេក្នុងការដោះស្រាយ និងទប់ស្កាត់នូវទំនាស់ផលប្រយោជន៍ជាសក្តានុពលដែលនឹងអាចកើតឡើង។

៣-បម្រើការងារក្នុងគណៈកម្មាធិការនានា ដូចជា គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំង ប្រសិនបើមាន ព្រមទាំងគណៈកម្មាធិការផ្សេងៗទៀត។

៤-ត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវការអនុវត្តរបស់ក្រុមហ៊ុន ដើម្បីសម្រេចបានតាមគោលបំណង និងគោលដៅដែលបានឯកភាព និងតាមដានការអនុវត្តការងារ។

**ប្រការ ៣២.-**

អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ ដែលនាំឱ្យរារាំងដល់ឯករាជ្យភាពរបស់ខ្លួនឡើយ។

អភិបាលឯករាជ្យ ៖

១-មិនត្រូវកាន់កាប់ភាគហ៊ុនក្រុមហ៊ុនលើសពី ០១ (មួយ) ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនឡើយ។

២-ត្រូវដាក់លិខិតបញ្ជាក់ថា មិនមានផលប្រយោជន៍សំខាន់ណាមួយនៅក្នុងក្រុមហ៊ុននៅពេលត្រូវបានតែងតាំង។

បុគ្គលមិនមានគុណវុឌ្ឍិជាអភិបាលឯករាជ្យ ប្រសិនបើខ្លួនគេ ឬសមាជិកគ្រួសាររបស់គេត្រូវបាន ៖

ក-ជួលឱ្យធ្វើការ ដោយ/ជា បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

ខ-បម្រើការងារជាសវនករផ្ទៃក្នុង ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុន។

គ-កំពុងបម្រើការងារជាសវនករផ្ទៃក្នុង ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុនដែលចូលរួមធ្វើសវនកម្មក្រុមហ៊ុននោះ ឬធ្លាប់បានធ្វើសវនកម្មផ្ទាល់លើក្រុមហ៊ុននោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

ឃ-កំពុងបម្រើការងារជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនធានារ៉ាប់រងដែលកំពុងធានារ៉ាប់រងឱ្យក្រុមហ៊ុននោះ។

ង-ជួលឱ្យធ្វើការ ដោយ/ជា បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលបុគ្គលិកជាន់ខ្ពស់នោះធ្លាប់ជាសមាជិកគណៈកម្មាធិការតបស្នងរបស់ក្រុមហ៊ុននោះ។

ច-បម្រើការងារជាបុគ្គលិកជាន់ខ្ពស់របស់អង្គភាព ឬអង្គការដែលទទួលបានវិភាគទានពីក្រុមហ៊ុន។

## ជំពូកទី ៦
## គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល

**ប្រការ ៣៣.-**

ដើម្បីធានានូវអភិបាលកិច្ចសាជីវកម្មល្អ ក្រុមប្រឹក្សាភិបាលត្រូវបង្កើតនូវគណៈកម្មាធិការមួយចំនួន ដូចខាងក្រោម ÷

-គណៈកម្មាធិការសវនកម្ម

-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ករណីទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈមានចំនួនចាប់ពី ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល។ ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល អាចបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ទៅតាមការចាំបាច់។

ដោយឡែក ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការផ្សេងទៀត ទៅតាមការចាំបាច់ និងតាមការណែនាំរបស់ **គ.ម.ក.**។

**ប្រការ ៣៤.-**

គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ និងសមាជិកដទៃទៀតត្រូវមានការយល់ដឹងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវតួនាទី និងភារកិច្ចជាអាទិ៍ ដូចខាងក្រោម ÷

-ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

-ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មខាងក្រៅ

-រាយការណ៍ទៅឱ្យក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន។

ប្រការ ៣៥.-

គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវមានតួនាទីគន្លឹះក្នុងការគ្រប់គ្រងហានិភ័យ នៅក្នុងកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុន។ គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិច ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ ឬគ្រប់គ្រងហានិភ័យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល។ តួនាទី និងភារកិច្ចអាចមានជាអាទិ៍ ដូចខាងក្រោម ÷

-ការវិភាគហានិភ័យ (Risk Analysis) រួមមាន ការពិពណ៌នាហានិភ័យ (Risk Description) ការកំណត់អត្តសញ្ញាណហានិភ័យ (Risk Identification) ការប៉ាន់ស្មានអំពីហានិភ័យ (Risk Estimation)

-ការវាយតម្លៃអំពីហានិភ័យ (Risk Evaluation)

-ការរាយការណ៍អំពីហានិភ័យ (Risk Reporting)

-ការលើកវិធានការទប់ទល់ហានិភ័យ (Risk Treatment)

-ការតាមដានអំពីហានិភ័យ (Risk Monitoring)

ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យអាចអនុវត្តដោយគណៈកម្មាធិការសវនកម្ម។

ប្រការ ៣៦.-

ករណីដែលមានគណៈកម្មាធិការតែងតាំង គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលសមាជិកទាំងអស់ត្រូវតែជាអភិបាលមិនប្រតិបត្តិ ដោយក្នុងនោះត្រូវមានសមាជិកយ៉ាងតិច ០១ (មួយ) រូប ជាអភិបាលឯករាជ្យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវការពិនិត្យ និងការវាយតម្លៃអំពីគុណវឌ្ឍិបេក្ខភាពអភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលត្រូវតែងតាំងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

គណៈកម្មាធិការតែងតាំងអាចមានការទទួលខុសត្រូវផងដែរ ចំពោះការរៀបចំនីតិវិធី ឬការពិនិត្យឡើងវិញ និងការផ្តល់អនុសាសន៍ សម្រាប់លាភការ និងប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។

## ជំពូកទី ៧
## ការធ្វើសវនកម្ម

**ប្រការ ៣៧.-**

ក្រុមប្រឹក្សាភិបាលត្រូវមានគណនេយ្យភាពចំពោះភាគហ៊ុនិក ហើយបុគ្គលិកជាន់ខ្ពស់ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ជូនភាគហ៊ុនិកនូវការវាយតម្លៃប្រចាំឆមាស ឬការកំណត់ផ្សេងទៀតដោយ **គ.ម.ក.** ឬវិធាននៃការចុះបញ្ជីលក់មូលបត្រ ដែលអាចទទួលយកបាន និងមានតុល្យភាព អំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន។ បុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវការវាយតម្លៃប្រចាំត្រីមាសដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន ហើយគួរតែរាយការណ៍ជូនក្រុមប្រឹក្សាភិបាលជារៀងរាល់ខែ អំពីហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុន។

**ប្រការ ៣៨.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវមានសវនកម្មផ្ទៃក្នុង។ សវនករផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម និងត្រូវមានការទទួលខុសត្រូវ និងកាតព្វកិច្ច ដូចខាងក្រោម ៖

១-បង្ហាញពីការវាយតម្លៃដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន។

២-រាយការណ៍អំពីដំណើរការធុរកិច្ចរបស់ក្រុមហ៊ុន និងបញ្ហាជាសក្តានុពល។

៣-រក្សាភាពរឹងមាំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីការពារផលប្រយោជន៍របស់ភាគហ៊ុនិក និងការវិនិយោគរបស់ភាគីពាក់ព័ន្ធ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

៤-អនុវត្តការស៊ើបអង្កេតសវនកម្មផ្ទៃក្នុងគ្របដណ្តប់ទៅលើការវាយតម្លៃពីភាពសមស្រប និងប្រសិទ្ធភាពនៃអភិបាលកិច្ច ប្រតិបត្តិការ និងប្រព័ន្ធព័ត៌មាន ដោយរាប់បញ្ចូលទាំងការការពារទ្រព្យសកម្ម និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ។

៥-ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់នូវរបាយការណ៍ប្រចាំឆ្នាំស្តីអំពីសកម្មភាពពាក់ព័ន្ធនឹងផែនការសវនកម្ម និងយុទ្ធសាស្ត្រដែលបានទទួលការយល់ព្រម

ពីគណៈកម្មាធិការសវនកម្ម។ របាយការណ៍ប្រចាំឆ្នាំនេះត្រូវរាប់បញ្ចូលទាំងការប្រឈមហានិភ័យ បញ្ហាត្រួតពិនិត្យ បញ្ហាអភិបាលកិច្ចសាជីវកម្ម និងបញ្ហាដទៃទៀតដែលស្នើដោយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។ គណៈកម្មាធិការសវនកម្មត្រូវតែផ្តល់របាយការណ៍ឱ្យភាគហ៊ុនិករបស់ក្រុមហ៊ុន ដែលជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។

៦-គណៈកម្មាធិការសវនកម្មត្រូវធានាថាសវនករផ្ទៃក្នុងមានសិទ្ធិទទួលបានព័ត៌មានទាំងស្រុងអំពីកំណត់ត្រា ទ្រព្យ និងបុគ្គលិកពាក់ព័ន្ធនឹងសកម្មភាពសវនកម្ម និងធានាថាសកម្មភាពសវនកម្មផ្ទៃក្នុង មិនទទួលរងការជ្រៀតជ្រែកក្នុងការកំណត់ពីវិសាលភាពនៃការត្រួតពិនិត្យ ការអនុវត្តការងារ និងការបញ្ជូនលទ្ធផលនៃការត្រួតពិនិត្យ។

**ប្រការ ៣៩.-**

ប្រធានសវនកម្មផ្ទៃក្នុងត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម ៖

១-មានសញ្ញាបត្រកម្រិតឧត្តមសិក្សាឡើងទៅដោយមានការបណ្តុះបណ្តាល ព្រមទាំងបទពិសោធន៍ខាងសវនកម្ម។

២-មានចំណេះដឹងស្តីពីបទដ្ឋានបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន។

៣-មានសមត្ថភាពក្នុងការដឹកនាំ និងចាត់ចែងបុគ្គលិកសវនកម្ម។

៤-ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមស្តង់ដារពាក់ពន្ធ័នឹងសវនកម្ម។

៥-មានជំនាញទំនាក់ទំនងល្អក្នុងការងារ។

៦-មានភាពស្មោះត្រង់ និងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ ៤០.-**

ប្រធានសវនកម្មផ្ទៃក្នុងមិនត្រូវអនុវត្តការងារដែលបង្កើតឱ្យមានទំនាស់ផលប្រយោជន៍។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម ៖

១-របាយការណ៍សវនកម្មដែលធ្វើដោយសវនករផ្ទៃក្នុងត្រូវផ្ញើទៅឱ្យគណៈកម្មាធិការសវនកម្ម ព្រមទាំងបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ និងបុគ្គលិកជាន់ខ្ពស់ដែលទទួលខុសត្រូវក្នុងផ្នែកដែលត្រូវបានធ្វើសវនកម្ម។

២-រាល់ការរកឃើញនានាដែលអាចមានផលប៉ះពាល់ដល់ដំណើរការរបស់ក្រុមហ៊ុនត្រូវបញ្ជូនទៅឱ្យគណៈកម្មាធិការសវនកម្ម។

៣-ត្រូវជួបជាមួយគណៈកម្មាធិការសវនកម្មយ៉ាងហោចណាស់ ០១ (មួយ) ដង ក្នុង ០១ (មួយ) ឆ្នាំ ដោយពុំចាំបាច់មានវត្តមានរបស់បុគ្គលិកជាន់ខ្ពស់ ។

៤-អនុវត្តការងារផ្សេងទៀតដែលគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាល ប្រគល់ជូន។

**ប្រការ ៤១.-**

សវនកម្មហិរញ្ញវត្ថុត្រូវអនុវត្តដោយសវនករឯករាជ្យដែលជ្រើសរើសដោយក្រុមប្រឹក្សា-ភិបាល តាមសំណើរបស់គណៈកម្មាធិការសវនកម្មក្នុងចំណោមក្រុមហ៊ុនគណនេយ្យជំនាញ ដែលទទួលស្គាល់ដោយ **គ.ម.ក.**។ អន្តរកម្មរវាងក្រុមហ៊ុនសាមី និងសវនករឯករាជ្យត្រូវស្ថិត នៅក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការសវនកម្ម។ ដើម្បីកម្រិតហានិភ័យនៃទំនាស់ ផលប្រយោជន៍ រាល់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម និងកម្រៃដែលត្រូវបង់ទៅ ឱ្យសវនករឯករាជ្យសម្រាប់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម ត្រូវតែទទួលបាន ការយល់ព្រមជាមុនពីគណៈកម្មាធិការសវនកម្ម ហើយត្រូវបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវផ្លាស់ប្តូរក្រុមហ៊ុនគណនេយ្យជំនាញ ដែលធ្វើសវនកម្ម ក្នុងរយៈពេលមិនលើសពី ០៣ (បី) ឆ្នាំ។ ក្រុមហ៊ុនបោះផ្សាយលក់ មូលបត្រជាសាធារណៈ មិនត្រូវប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនគណនេយ្យជំនាញដដែល ឡើងវិញ ក្នុងរយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់ពីកិច្ចសន្យាប្រើប្រាស់សេវាកម្មមុនត្រូវបាន បញ្ចប់។ ក្នុងគោលបំណងជៀសវាងនូវទំនាស់ផលប្រយោជន៍ ក្រុមហ៊ុនគណនេយ្យជំនាញ មិនត្រូវផ្តល់សេវាកម្ម ដូចជា សវនករផ្ទៃក្នុង សេវាកម្មបញ្ជិកាគណនេយ្យ ការបង្កើតនិង អនុវត្តន៍ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ សេវាកម្មវាយតម្លៃ សេវាកម្មពាក់ព័ន្ធនឹងការកំណត់ សោធននិវត្តន៍បុគ្គលិករបស់ក្រុមហ៊ុន និងសេវាកម្មដទៃទៀតដែលអាចបង្កឱ្យមានទំនាស់ ផលប្រយោជន៍។

**ប្រការ ៤២.-**

រាល់ការសុំឈប់ ការបញ្ឈប់ ឬការផ្អាកសេវាកម្មសវនកម្មរបស់ក្រុមហ៊ុនគណនេយ្យ ជំនាញត្រូវមានការបញ្ជាក់នូវហេតុផលឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ភ្លាមក្នុងរយៈពេលមិនលើសពី ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ របាយការណ៍ប្រចាំឆ្នាំត្រូវបញ្ចូល ការពិភាក្សាអំពីការមិនយល់ស្របរបស់

អតីតក្រុមហ៊ុនគណនេយ្យជំនាញទៅលើបញ្ហាគោលការណ៍ និងការអនុវត្តគណនេយ្យ ទៅលើការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងវិសាលភាពនៃសវនកម្ម ឬលើនីតិវិធីសវនកម្មដែលមិនមានដំណោះស្រាយធ្វើឱ្យពេញចិត្តអតីតក្រុមហ៊ុនគណនេយ្យជំនាញ។

**ប្រការ ៤៣.-**

សវនករឯករាជ្យត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

១-ត្រូវផ្តល់នូវទស្សនៈឯករាជ្យ និងប្រាកដនិយមថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ក្រុមហ៊ុន ស្របទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ ដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ត្រូវអនុវត្តតាមស្តង់ដារសវនកម្ម ដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ជំពូកទី ៨**

**ភាគីពាក់ព័ន្ធ**

**ប្រការ ៤៤.-**

ឥណទាយក បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ ឬមានកិច្ចសន្យាជាមួយក្រុមហ៊ុន ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ រាល់ភាគីពាក់ព័ន្ធទាំងអស់របស់ក្រុមហ៊ុនត្រូវទទួលបាននូវការការពារសិទ្ធិ។ ក្រុមហ៊ុនត្រូវធានាការការពារសិទ្ធិដល់ភាគីពាក់ព័ន្ធជាអាទិ៍ ដូចខាងក្រោម ៖

១-ត្រូវមានគោលនយោបាយគ្រប់គ្រងយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីគាំទ្រ និងការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ។

២-ត្រូវធានាការអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

៣-មិនត្រូវធ្វេសប្រហែសចំពោះការទទួលខុសត្រូវសង្គម ដូចជាការការពារអ្នកប្រើប្រាស់ និងការការពារបរិស្ថាន។

៤-ទទួលស្គាល់ និងការពារសិទ្ធិដាច់ចេញពីគ្នានៅពេលដែលបុគ្គលជាភាគីពាក់ព័ន្ធ និងជាភាគហ៊ុនិក។

**ប្រការ ៤៥.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យភាគីពាក់ព័ន្ធដូចជា ឥណទាយក និងនិយោជិត នូវព័ត៌មានពាក់ព័ន្ធដែលចាំបាច់ដើម្បីតាមដាននូវដំណើរការរបស់ក្រុមហ៊ុន ព្រមទាំងត្រូវការពារសិទ្ធិរបស់ពួកគេ។

## ជំពូកទី ៩
## ការបង្ហាញព័ត៌មាន និងតម្លាភាព

**ប្រការ ៤៦.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងក្រុមហ៊ុនតាមរយៈយន្តការទីផ្សារ ដូចជា ÷

១-យន្តការត្រូវធ្វើឡើងតាមរយៈនីតិវិធីប្រកបដោយយុត្តិធម៌ និងមានតម្លាភាពនៅពេលដែលមានសកម្មភាពនាំឱ្យមានការផ្លាស់ប្តូរក្នុងការត្រួតត្រាក្រុមហ៊ុន ដូចជា ការទទួលកាន់កាប់បន្ត (Takeovers) ការរួមបញ្ចូល (Mergers) ការទិញយក (Acquisitions) និងការផ្ទេរអាជីវកម្ម (Transfers of business)។

២-យន្តការទាក់ទងនឹងសកម្មភាពការពារក្រុមហ៊ុនឱ្យផុតពីការការត្រួតត្រា ដោយធ្វើយ៉ាងណាសកម្មភាពការពារនោះមិនត្រូវឱ្យមានការលះបង់ផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក។ ប្រសិនបើសកម្មភាពការពារនោះតម្រូវឱ្យមានការលះបង់ផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក ការលះបង់ផលប្រយោជន៍នោះត្រូវមានការយល់ព្រមពីភាគហ៊ុនិក។

៣-យន្តការចាំបាច់នានាក្នុងការចាត់វិធានការប្រឆាំងនឹងការទទួលកាន់កាប់បន្តអមិត្ត (Hostile takeovers) ដូចជា ការទិញភាគហ៊ុនត្រឡប់មកវិញក្នុងបំណង ដើម្បីការពារការត្រួតត្រាក្រុមហ៊ុនដែលការទិញភាគហ៊ុនត្រឡប់មកវិញនេះត្រូវធ្វើការប្រកាសឱ្យបានលម្អិត ដើម្បីឱ្យភាគីពាក់ពន្ធ័យល់ដឹងពីហេតុផលនិងអាចព្យាករណ៍បាននូវផលវិបាកដែលអាចកើតឡើង។

**ប្រការ ៤៧.-**

ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មាន ទាន់ពេល និងមានប្រសិទ្ធភាព ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិ និងពត៌មានផ្សេងទៀតដែលអាចមានផលប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភាគហ៊ុនិក និងភាគីពាក់ពន្ធ័ដទៃទៀត។

ព័ត៌មានសំខាន់ៗដែលទាក់ទងនឹងអភិបាលកិច្ចសាជីវកម្ម ដែលក្រុមហ៊ុនត្រូវបង្ហាញ រួមមាន ៖

១-សមាសភាពក្រុមប្រឹក្សាភិបាល រួមទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ អភិបាលឯករាជ្យ រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល រចនាសម្ព័ន្ធគ្រប់គ្រង គោលនយោបាយលើកទឹកចិត្ត គោលនយោបាយពាក់ព័ន្ធទំនាស់ផលប្រយោជន៍ និងក្រមសីលធម៌របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

២-សិទ្ធិ តួនាទី និងភារកិច្ច និងសកម្មភាពនៃគណៈកម្មាធិការនានារបស់ក្រុម-ប្រឹក្សាភិបាល។

៣-សកម្មភាពរបស់អភិបាលម្នាក់ៗ និងក្រុមប្រឹក្សាភិបាល។

៤-ដំណើរការប្រព័ន្ធបោះឆ្នោតត្រួត ករណីទទួលបានការអនុម័តពីភាគហ៊ុនិក។

**ប្រការ ៤៨.-**

ក្រុមហ៊ុនត្រូវរៀបចំព័ត៌មានដើម្បីធ្វើការបង្ហាញក្នុងទម្រង់ងាយយល់ ដោយជៀសវាងការប្រើប្រាស់ពាក្យដែលមានន័យមិនច្បាស់លាស់ និងពាក្យបច្ចេកទេសស្មុគស្មាញ។ ការបង្ហាញព័ត៌មានជាសាធារណៈត្រូវធ្វើយ៉ាងណាងាយទទួលបាន និងមានតម្លៃទាប។ ចំពោះពាក្យបច្ចេកទេសស្មុគស្មាញទាំងនោះ ក្រុមហ៊ុនត្រូវរៀបចំឱ្យមានការពន្យល់ភ្ជាប់មកជាមួយ ដើម្បីឱ្យសាធារណជនទូទៅបានយល់។

ករណីឯកសារដែលត្រូវបង្ហាញធ្វើឡើងជាភាសាបរទេសក្រុមហ៊ុនត្រូវតែរៀបចំបកប្រែឯកសារទាំងនោះមកជាភាសាខ្មែរដោយភ្ជាប់ងារបកប្រែដែលទទួលស្គាល់ដោយ **គ.ម.ក.**។

ក្រុមហ៊ុនត្រូវចាត់តាំងបុគ្គលិកម្នាក់ ដើម្បីទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មាន រួមទាំងការរាយការណ៍ទៅទីផ្សារ និង **គ.ម.ក.** ដោយក្រុមប្រឹក្សាភិបាល និងត្រូវមានប្រព័ន្ធត្រួតពិនិត្យព័ត៌មានផ្ទៃក្នុង (Internal Information Control System) ដែលអាចបញ្ជូនព័ត៌មានសំខាន់ៗរបស់ក្រុមហ៊ុនឱ្យបានឆាប់រហ័សដល់បុគ្គលិកនោះ។ ដើម្បីបញ្ជូនព័ត៌មានដល់សាធារណជនឱ្យបានទាន់ពេល ត្រឹមត្រូវ និងមានប្រសិទ្ធភាព បុគ្គលិកដែលទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានត្រូវមានសិទ្ធិទទួលបានព័ត៌មានភ្លាមៗរបស់ក្រុមហ៊ុន។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**ប្រការ ៤៩.-**

បុគ្គលណាមួយដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការរដ្ឋបាល ដូចខាងក្រោម ៖

-ការព្រមាន

-ការណែនាំឱ្យកែតម្រូវកំហុស

-ការព្យួរជាបណ្តោះអាសន្ន ឬការបញ្ឈប់ការងាររបស់អភិបាល និង/ឬ បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

-ការព្យួរ ឬការលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

-ការព្យួរ ឬការបញ្ឈប់ការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៥០.-**

បុគ្គលណាមួយដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៥១.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ភាគី ឬបុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងសាធារណជន។

**ប្រការ ៥២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៣.** –

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀត ចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១០

**គាត ឈន់**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-គណៈកម្មការមូលបត្រកម្ពុជា
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៥៣
"ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ២០០ ឧ.រ.ថ.ក.ឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០

លិខិតចូល

ថ្ងៃទី៩៣ ខែមីនា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ១៣៤៧/០៧ ក.វ.ក ចុះថ្ងៃទី២៤.០៤.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ជី-ហ្វម៉ូស ចុះថ្ងៃទី១៣.០១.២០១០

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យក្រុមហ៊ុន ជី-ហ្វម៉ូស តំណាងដោយ លោក តៃ ជូវ សញ្ជាតិ ខ្មែរអាយុ៣៨ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010360436 ចុះថ្ងៃទី ០២.០៤.២០០៤ មានអាសយដ្ឋានបច្ចុប្បន្ន : ផ្ទះលេខ ២៧០បេ ផ្លូវ១៨២ ក្រុម១០ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម :

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| **ស្បែកជើង** | **៣២៤០** |

-ផ្លាកឈ្មោះ រោងចក្រ : **ជី-ហ្វម៉ូស** (G-FOREMOST CO., LTD.)

-ទីតាំងរោងចក្រ : *"ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្ដាល"*

**ប្រការ២** : -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការ ត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រមិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជី មុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣** : -ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និង រាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្ដីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្ដីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូឆ្នាំ១៩៩៦ និងរាល់អនុក្រឹត្យនានាស្ដីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤** : ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥** : ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយ ប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឱ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦** : ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណៈជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧** : -មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។/ ...

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម :

**ក.**ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

**ខ.**ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

**គ.**ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ជិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ។

**ប្រការ៨** : -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្រប ណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩** : -ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុង អំឡុងពេលសប្តាហ៍ទីមួយនៃខែមករានៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០**: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់អំពី អត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះ បញ្ជីផលិតផល ។

**ប្រការ១១**: លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។/.

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

**ប្រការ១៤:** ប្រកាសលេខ ៤៨០ ឧរថ.កឧ.ប្រក ចុះថ្ងៃទី៣១.០៥.២០០៧ និងវិញ្ញាបនបត្រលេខ ៤៩ ឧរថ.កឧ.បរ ចុះថ្ងៃទី៣១.០៥.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពី ការបង្កើតរោងចក្រ ផលិតស្បែកជើង របស់ក្រុមហ៊ុន ជី-ហ្វម៉ូស ដែលមានទីតាំងស្ថិតនៅ ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង ម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦:**

ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រាជកិច្ច
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- -ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងពាណិជ្ជកម្ម
- -សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាប "

-ដូចប្រការ១៥ " ដើម្បីអនុវត្ត "

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៩៨៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **អិល អឹម អេស ខេ ត្រេឌីង**

**LMSK TRADING Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 13534/09P** ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **លីម ស៊ីយ៉ាំង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៤ ផ្លូវលេខ ៧ បុរីពិភពថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
- -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
- -ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
- -មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
- -បើកសាលារៀន
- -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
- -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- -សេវាផ្សាយពាណិជ្ជកម្ម
- -បោះពុម្ពផ្សាយ
- -ផលិតខ្សែភាពយន្ត វីដេអូ CD
- -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ធនាគារជាតិ នៃកម្ពុជា-ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍-ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៩៨៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **កំពង់សោម ស៊ីបផ្លាយយីង ខនស្ត្រាក់ស៊ិន**

**KAMPONG SOM SUPPLYING CONSTRUCTION Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 13539/09P** ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩

មានទម្រង់ទ្រព្យជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ណាង សុរិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ណាង សុគន្ធា** អភិបាល

លោក **អ៊ុង ឧត្តី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៦៥ BE1 ផ្លូវលេខ ១៨២ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋមន្ត្រីស៊ីធី**

**ភឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន-ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**

លេខ ១៨៩៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **គង់ សំអូន**

**KONG SAM AUN Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 13537/09P ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ឥត ចំនួនស្មី** ប្រធានក្រុមប្រឹក្សាភិបាល

លោក **គង់ សំអូន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិសំបួរ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ៍រណ៍ អាហារ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស សេវាបញ្ជូន និង ចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ព្រះរាជាណាចក្រកម្ពុជា ក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន-ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាខេត្តតាកែវ
- មន្ទីរពាណិជ្ជកម្មខេត្តតាកែវ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសខ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៩៩៣ ពណ.ចបព

ភ្នំពេញថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប្រុកធើ & ហ្គេមបិល ឌីស្ទ្រីប៊ុធីង (ខេមបូឌា)**
PROCTER & GAMBLE DISTRIBUTING ( CAMBODIA ) Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 13550/09P ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៩

មានទម្រង់ព្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ស៊ីង អ៊ែត** ប្រធានក្រុមប្រឹក្សាភិបាល
កញ្ញា **ឈាន ចិន្តា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២៤៨ E2 ផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបពាន និងបែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ...

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/៖

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**កឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន -ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- បន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "បុខការ"

៤៩ - ឯកសារ -កាលប្បវត្តិ